
sabay
FREE!
FOREVER YOUNG
ISSUE #31/DECEMBER 2014
A MONTHLY CAMBODIAN ENTERTAINMENT & LIFESTYLE GUIDE

# the taste of FRENCH CUISINE

# ម្ហូបបារាំងពិតៗ



















LE BISTROT
DE L'INSTITUT FRANÇAIS

OPEN from Monday to Saturday
7.30am-10pm
Institut français (French Institute)
#218 street 184, Phnom Penh
Reservation: 012 495 841

នៅវិទ្យាស្ថានបារាំង
(អតីតសាលាអាលីយ៉ង់)
អាគារ ២១៨ ផ្លូវ ១៨៤ - រាជធានីភ្នំពេញ
កក់កន្លែង : ០១២ ៤៩៥ ៨៤១

www.cellcard.com.kh

# ទិញសំបុត្រទស្សនាភាពយន្ត 2 សន្លឹក នៅរោងភាពយន្ត MAJOR CINEPLEX

# ទទួលបាន ពោតលីង ដោយឥតគិតថ្លៃ

## សម្រាប់តែអតិថិជន XG ប៉ុណ្ណោះ

XG



MAJOR CINEPLEX by Cellcard

ទូរស័ព្ទទៅលេខ 1818 ដើម្បីទទួលបានលេខកូដរបស់លោកអ្នកសម្រាប់ប្តូរយកពោតលីង
កម្មវិធីនេះផ្តល់ជូន ចាប់ពីថ្ងៃទី14 ខែវិច្ឆិកា ឆ្នាំ2014 រហូតដល់មានការជូនដំណឹងផ្សេងទៀត

cellcard

# CONTENT
ISSUE 31


6 Dr.FASHION

8 FASHION

12 ក្លឹប ជាឌីជេ វ័យក្មេងល្បីឈ្មោះ

13 ក្រុមអ្នកចម្រៀង RAP ថ្មី Khmer Pride

38 រឿងរ៉េវរ៉េមអ្នកគួរដឹង Dessert Storyមាននៅកម្ពុជា


14 មណ្ឌលគីរីធម្មជាតិស្រស់បំព្រងក្នុងរដូវប្រាំង


16 GADGET FREAK


17 CCC 2014


26 TACOS IN PHNOM PENH


24 THAILAND MOTOR EXPO


31 វិធីផាត់មុខតាមអ្នកជំនាញ





SREYMOM PHAT
Sales Manager / Advertisement
089 777 670
phat.sreymom@cidc.com.kh
www.sabay.com.kh



ប្រធានផ្នែកគ្រប់គ្រង | Editor: លុក វណ្ណរង្គ Luok Vannrong
ផ្នែករៀបចំ និង រចនា | Graphic Designer: លីវ ប៉ូលីន Liv Polin
អ្នកសម្របសម្រួល | Coordinator: លី សុផាត Ly Sophat
ផ្នែកថតរូប | Photographer: SEM, លន ហ្សាឌីណា Lon Jadina, Liv Polin
ផ្នែកព័ត៌មាន | Writers: យិន សំបូរ, អ៊ុង សុទ្ធា, ប៉ែន សុផាន់ណា, អ៊ុំ សុភក្តិ, វិចទ័រ រ៉ូលីន
អាសយដ្ឋាន អគារ ៣០៨ មហាវិថីព្រះមុនីវង្ស រាជធានី ភ្នំពេញ បោះពុម្ពផ្សាយ៖ ប្រទេសកម្ពុជា, រោងពុម្ព៖ ព្រីន ម៉ាស្ទ័រ
ទំនាក់ទំនងការិយាល័យ Phone: (855) 023 228 000 /Fax: (855) 23 218 588
អ៊ីមែល៖ info@cidc.com.kh /www.sabay.com


## EDITORS NOTE

សួស្តីមិត្តអ្នកអានទាំងអស់គ្នា!

ស្វាគមន៍ការមកកាន់លេខទី ៣១ « Stay Young » ទស្សនាវដ្ដី Sabay Magz ! លេខថ្មីនេះយើងផ្តោតទៅលើការរក្សាភាពវ័យក្មេងរបស់មនុស្សដែលអាចឆ្លុះបញ្ចាំងតាមរយៈរូបរាង ទឹកមុខ ចិត្តគំនិត និងបញ្ញាស្មារតី។

ជាការពិតមួយដែលមនុស្សគ្រប់រូបមិនចង់ចាស់មុនអាយុ ឬក៏បណ្តោយឱ្យភាពចាស់ទាំងនោះចូលមកក្នុងខ្លួនអ្នកបានដោយងាយនោះទេ ជាពិសេសគឺលើរូបសម្រស់តែម្តង។ សម្រាប់ខ្លួនខ្ញុំផ្ទាល់អាយុគ្រាន់តែជាតួលេខប៉ុណ្ណោះ ! អ្វីដែលត្រូវផ្តោតសំខាន់នោះ គឺភាពរីករាយក្នុងជីវិតនិងសិល្បៈនៃការរស់នៅ។

ប្រិយមិត្តជាទីមេត្រី! ទំព័របន្ទាប់ទៀតនេះមិត្តអ្នកអាននឹងបានជួបនូវរឿងរ៉ាវមួយចំនួនដែលយុវវ័យប្រើប្រាស់ភាពវ័យក្មេងពួកគាត់ក្នុងការសម្រេចការងារ អាជីវកម្ម និងគម្រោងផ្សេងៗនៅថ្ងៃអនាគតរបស់ពួកគេ។ ចំណែកឯទំព័រ Fashion វិញ អ្នកនឹងបានឃើញ យុវតីក្មេងៗទាំង ៣ រូបសើច ញញឹមញញែមដាក់អ្នកប្រកបដោយទំនុកចិត្ត ដែលមើលទៅក្មេងហើយស្រស់ស្អាតថែមទៀតផង។

ក្រៅពីនេះយើងក៏មានបង្ហាញពីអត្ថបទផ្សេងៗពាក់ព័ន្ធការធ្វើដំណើរទៅកាន់ខេត្តមណ្ឌលគីរី សកម្មភាពប្លែកៗក្នុងថ្ងៃណូអែលនៅ Kid City វិធីផាត់មុខឱ្យក្មេងជាងវ័យ និងអត្ថបទជាច្រើនទៀតដែលទើបតែកើតឡើងថ្មីៗក្នុងខែនេះ។

ក្នុងនាមជាទស្សនាវដ្ដីដែលបង្ហាញពីសិល្បៈនៃភាពស៊ីវិល័យរបស់យុវវ័យ ក្រុមការងារទស្សនាវដ្ដីនឹងខិតខំប្រឹងប្រែងបន្តទៀតក្នុងការ
លើកយកអ្វីដែលថ្មីមកបង្ហាញជូនដល់មិត្តអ្នកអានទាំងអស់គ្នានៅខែក្រោយៗទៀត។ អរគុណដល់ប្រិយមិត្តទាំងអស់គ្នាដែលតែងតែគាំទ្រ Sabay Magz! ជូនពរមិត្តទាំងអស់គ្នាជួបតែសំណាងល្អនិងសុខភាពល្អគ្រប់ពេលវេលា។

ពីខ្ញុំ តុង

VOXPOP

# តើល្បែងកម្សាន្តណាខ្លះ ដែលរំឮកអ្នកកាលពីវ័យកុមារ?

កុមារភាពជាវ័យដែលអាចនិយាយបានថាមានភាពរីករាយជាងគេដោយមិនបាច់ខ្វល់ខ្វាយពីអ្វីទាំងអស់។ តើមានល្បែងកម្សាន្តណាខ្លះដែលធ្វើអោយយុវវ័យស្រណោះនឹកឃើញដល់វ័យកុមារ ?
Childhood might as well be the best time of your life. It's when you're free to do whatever you want, no matter how silly, without any worries. Though now you're not a child anymore, is there any particular games reminded of the child in you?



**យុវតី សុខ កញ្ញា អាយុ២២ឆ្នាំ បុគ្គលិកជំនួយការផ្ទាល់ខ្លួនបាននិយាយថា៖**
"ល្បែងកម្សាន្តដែលអោយខ្ញុំនឹកឃើញដល់កាលនៅក្មេងមានដូចជាពង្រាត់កូនក្រមុំ លោតកៅស៊ូ លោតមឹកអីហ្នឹង។ បើពេលណាបានឃើញក្មេងលេងល្បែងអស់ហ្នឹងខ្ញុំនឹកកាលពីក្មេងបើប្រមូលគ្នីគ្នាមកច្រើនអីសប្បាយណាស់"

**SOK KANHA, 22, PERSONAL ASSISTANT:**
" I remember I used to play games like the jumping rope, chasing the bride, etc. When I see kids playing games like that, I think of how fun it was gathering a lot of friends to goof around just like that."



**យុវជន សំអាត វ៉នយ៉េន អាយុ២១ឆ្នាំ និស្សិតនៃមហាវិទ្យាល័យ PPIU៖**
"ខ្ញុំចាំបានថាកាលពីក្មេង ចូលចិត្តប្រមូលគ្នាលេងបាញ់ឃ្លីមុខផ្ទះពេលចេញពីរៀន និងចុងសប្តាហ៍។បើខែត្រជាក់អីចឹងវិញ លេងឃ្លីសប្បាយណាស់ ព្រោះដីអត់មានភក់ហើយ ត្រជាក់ស្រួលអត់បែកញើសទៀត។ ពេលខ្លះលេងភ្នាល់ដាក់លុយ និងតុក្កតារូបសត្វក៏មាន។ដល់ពេលធំទៅឃើញក្មេងៗលេងនឹកអស់សំណើច បើឥលូវខ្ញុំអាចទៅលេងល្បែងអស់ហ្នឹងបាន ខ្ញុំលេងឈ្នះគេមិនខាន"

**SOMATH VORN YEN, 21, A SENIOR STUDENT FROM PPIU:**
"I remember as a kid, we like to gather around and play pebbels in front of our houses after school and on weekends. During cool season like this, it's perfect for pebble games as the ground won't be muddy and it's not too hot to play outside. Sometimes we play and bet money and toys too. I feel funny that I see them play now. Make me wanna be young again and beat them with my experience.



**យុវតី សួ ច័ន្ទមិនា អាយុ21ឆ្នាំ ជានិស្សិតនៃមហាវិទ្យាល័យ CamEd ៖**
"កាលពីក្មេងធ្លាប់បានលេងល្បែងកម្សាន្តអស់ហ្នឹងច្រើនណាស់ដូចជា ២ដក១ ពង្រាត់កូនក្រមុំ លេងខ្វងជាដើម។ ពេលខ្លះបានឃើញក្មេងៗលេងល្បែងកម្សាន្តដូចខ្ញុំកាលពីក្មេង មានអារម្មណ៍ថាសប្បាយចិត្តផង តែក៏ដូចជាច្រណែនតិចព្រោះមិនអាចរត់លេង សើចសប្បាយសេរីដូចពីមុន។

**SOUR CHAN MINEA, 21, A STUDENT FROM CAMED:**
" I used to play games like 2 minus 1, chasing the bride, and some sort of tag games. I got mix feelings when I see children playing the games I played before. On one hand, I feel happy but I also feel jealous that I cannot run around and laugh freely like before. I'd want to go back in time and be young again."

ចំពោះប្រិយមិត្តដែលកំពុងអាន Sabay Magz រស់នៅអោយសប្បាយទាន់ខ្លួននៅក្មេង!
To all our beloved readers, preserve the child in you, live while you're young!

អត្ថបទ: រ៉ូលីន




mleng.sabay.com 023 883 000

# ម៉ូដខោអាវខ្មែរសម័យថ្មី

## រចនាដោយអ្នកច្នៃម៉ូដវ័យក្មេង Dr.Fashion



និយាយដល់ម៉ូដខោអាវខ្មែរ ប្រិយមិត្តទាំងអស់គ្នាប្រហែលជានឹកដល់ម៉ូដខោអាវបែបប្រពៃណីមុនគេ ព្រោះថាហាងកាត់សំលៀកបំពាក់បែបប្រពៃណីនៅភ្នំពេញមានច្រើនស្ទើររាប់មិនអស់ ចំណែកឯហាងខោអាវម៉ូដសម័យទំនើបដែលរចនា និងដេរដោយកូនខ្មែរវិញ ហាក់បីដូចជានៅឆ្ងាយពីភ្នែកប្រជាជនក្នុងស្រុកបន្តិច បើធៀបនឹងម៉ូដខោអាវនាំចូលពីប្រទេសជិតខាង។ ដោយមើលឃើញបែបនេះ យុវជន ហុង ឈិន និស្សិតបញ្ចប់ថ្នាក់បរិញ្ញាផ្នែក Fashion Design ពីសាកលវិទ្យាល័យ LimkokWing សម្រេចចិត្តបើកអាជីវកម្មផ្ទាល់ខ្លួនមួយ ក្នុងគោលបំណងពីរ ទីមួយគឺចង់បង្កើនសមត្ថភាពផ្នែកច្នៃម៉ូដចំណែកឯគោលដៅទីពីរវិញ គឺចង់ឱ្យប្រជាជនខ្មែរដឹងថា ខ្មែរក៏មានម៉ូដខោអាវសម័យថ្មីដូចប្រទេសជិតខាងដែរ។

Dr.Fashion ជាឈ្មោះដែលយុវជនខាងលើប្រើសម្រាប់ដាក់ឈ្មោះហាងផង និងជាឈ្មោះម៉ូដខោអាវផង។ ស្ថាបនិកបង្កើតម៉ាក Dr.Fashion នេះបាននិយាយប្រាប់ទស្សនាវដ្ដី Sabay ថា ឈ្មោះនេះមិនសំដៅលើកម្រិតថ្នាក់បណ្ឌិតច្នៃម៉ូដអីនោះទេ ឈ្មោះនេះគ្រាន់តែដាក់ឲ្យឃើញថាប្លែកតែប៉ុណ្ណោះ និយាយរួមស្រួលស្ដាប់ និងស្រួលហៅ។

យុវជន ហុង ឈិនបន្តថា យុវវ័យសម័យថ្មីភាគច្រើនឲ្យតែនឹកឃើញដល់ការលេងម៉ូដខោអាវកាលីបៗ គឺតែងនឹកដល់ប្រទេសជិតខាង ហើយពេលខ្លះពួកគាត់សុខចិត្តធ្វើដំណើរទៅក្រៅប្រទេសដើម្បីទិញទៀតផង។ មូលហេតុនេះហើយដែលនាំឲ្យរូបលោក បើកហាងតូចមួយដើម្បីផ្គាប់ចិត្តយុវវ័យក្នុងស្រុកមួយចំនួនឲ្យងាកមករកមើលម៉ូដខោអាវសម័យថ្មីដែលធ្វើដោយកូនខ្មែរវិញម្ដង។

" ខ្ញុំនៅក្មេង! តែវភ្នែកខ្ញុំគឺស្ថិតមិនឆ្ងាយពីការលេងខ្លួនរបស់យុវវ័យឡើយ ដូច្នេះម៉ូដដែលខ្ញុំធ្វើឡើងដោយខ្លួនឯងទាំងអស់នោះ ខ្ញុំជឿថាយ៉ាងហោចណាស់ក៏មានកន្លែងទាក់ទាញណាមួយ អាចផ្គាប់ចិត្តពួកគាត់បានខ្លះដែរ ”។ Dr.Fashion បញ្ជាក់។

ហាង Dr.Fashion បច្ចុប្បន្ននេះ មានរចនាម៉ូដខោអាវបុរសនារីជាច្រើនមានដូចជា អាវយឺត អាវក្រណាត់ ខោវែងនិងខ្លី កន្សែងបង់ក សំពត់ រ៉ូប និងឈុតសម្រាប់នារីពាក់ចូលរួមកម្មវិធីសំខាន់ៗផងដែរ។ ហុង ឈិន បានលើកឡើងថា គ្រប់ម៉ូដដែលរចនាឡើងគឺដេរដោយដៃផ្ទាល់ ដែលភាគច្រើនផ្ដោតតាមរដូវ និងតាមចំណូលចិត្តផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ដូច្នេះបានជានៅក្នុងហាង Dr.Fashion មានច្រើនម៉ូដទាំងខោអាវប្រុសនិងស្រី។
ក្រៅពីបង្ហាញស្នាដៃនៅក្នុងហាងផ្ទាល់ខ្លួន យុវជន ហុង ឈិន ក៏ធ្លាប់បានរចនាម៉ូដខោអាវដល់តារាចម្រៀងខ្មែរមួយចំនួនទៀតផង តារាទាំងនោះមានដូចជា លោក ម៉ានិត ច្រៀងនៅផលិតកម្មភ្លេង Record លោក ម៉ា ច័ន្ទបញ្ញា យុវជនឆ្នើមទើបទទួលបានមេដាយ Fashionable Singer និងតារាជាច្រើនតាមបណ្ដាផលិតកម្មធំៗ។

Fashion អាចនិយាយបានថាជាការងារពិបាកមួយដែលត្រូវប្រើគំនិតច្នៃប្រឌិតច្រើន ម្យ៉ាងទៀតឧស្សាហកម្មសំលៀកបំពាក់ពីក្រៅស្រុកក៏ជាផ្នែកមួយធ្វើឱ្យមានការប្រកួតប្រជែងផងដែរ។ លើកដល់ចំណុចនេះ អ្នកច្នៃម៉ូដវ័យ ២២ ឆ្នាំរូបនេះ និយាយដោយមិនលាក់លៀមថា ការពិតទៅគ្រាន់តែគំនិតចង់បោះបង់ចោល គឺមានច្រើនដងមកហើយ តែគិតឲ្យសព្វៗទៅ បើដើរដល់ពាក់កណ្ដាលផ្លូវហើយ មានរឿងអីត្រូវបោះបង់ចោល អីចឹងមានតែខំប្រឹងបន្តទៀត ណាមួយមានក្រុមគ្រួសារ និងមិត្តភ័ក្ដិជាអ្នកផ្ដល់កម្លាំងចិត្តថែមទៀត ដូច្នេះការបោះបង់ចោលបានឃ្លាតឆ្ងាយពីការគិតរបស់លោកបាត់អស់ហើយ។

មេរៀនមួយដែលយុវជន ហុង ឈិន ទទួលបានពីការបើកហាងច្នៃ និងផលិតសំលៀកបំពាក់ដោយខ្លួនឯង ចង់ប្រាប់ដល់យុវវ័យទាំងអស់គ្នាថា៖ “ មនុស្សវ័យក្មេងតែងមានគំនិតចង់ផ្លាស់ប្ដូរច្រើន តែពេលខ្លះបើសិនជាគិតមិនបានគ្រប់ជ្រុងជ្រោយនោះទេ ការផ្លាស់ប្ដូរអាចនឹងផ្ដល់គុណវិបត្តិមួយចំនួន អាចជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃ ដូចជាខ្ញុំអ៊ីចឹង! បើតាមតែចិត្តឆេវឆាវខ្លួនឯងមួយពេលៗ មិនដឹងថាពេលនេះឈ្មោះ Dr.Fashion នៅណាទេ ដូច្នេះការសម្រេចចិត្តរបស់មនុស្សនៅអាយុស្របាលខ្ញុំនេះ ត្រូវប្រាកដថាហ៊ានទទួលយកលទ្ធផលឬក៏អត់បន្ទាប់ពីសម្រេចចិត្តដោយខ្លួនឯង”។

New Fashion Line
by Young Khmer Designer, Dr. Fashion

When we talk about Khmer fashion, the first thing that pops up in our mind is our traditional clothing that is everywhere in Phnom Penh. However, modern design and tailor parlors are still far fetch from the local's eyes comparing to other neighboring countries. This leads Hong Chinn to open his own business aiming to improve designing sector and make known to Cambodian people that we also design our own modern clothing collections.

Chinn said that Dr. Fashion is both the shop and brand name. It doesn't specify that he is a doctor in this industry, but simply, it's unique and easy to roll off our tongue.

Hong Chinn added that most teenagers think of cool clothes as of foreign countries. Sometimes they even go abroad for the sole purpose of shopping. Consequently, he decided to create this own shop to accommodate teens to try local brand by Khmer designers for a change.

“I'm young. But my vision is not that much different from teenagers, so what I design bound to have something that attracts them,” Dr. Fashion noted.

Currently Dr. Fashion designs clothes for both men and women such as Tee, shirts, pants both long and short, scarves, skirts, dresses for ladies to attend special occasions. Hong Chinn said that his designs focus on the season and favors of individuals, resulted in many different types of designs in his store.

On top of that, Chinn also designed clothes for celebrities such as Mr. Manith from Pleang Record, Mr. Ma Chanpanha, a model teen and many other TV personalities.

Working in fashion is hard as it demands a lot of creativity and the industry is very competitive. Our 22-year-old designer stated that there are many times he wanted to quit but he couldn't abandon his work half way. There are friends and families to support him so now he doesn't plan to give up on this anymore.

The lesson learned is that, “ Young people tend to change a lot. And there are times that they don't consider on every aspect, which may result negatively. Just like me, if I had acted on a whim, there wouldn't be Dr. Fashion anymore. Decision making of people around my age have to ensure that you'll own up to the consequences of your choices.”

# CHINN FASHION DESIGNER



A

សាខាធំៈសាខាទី៦ ផ្លូវព្រះសីហនុ
ខាងកើតអតីត រោងកុន គិរីរម្យចាស់
ចម្ងាយប្រហែល ២០០ម៉ែត្រ
បញ្ចុះតម្លៃពិសេស ១០% - ២០%
នៅសាខាទី៩តែមួយគត់

B M-SHOP

No: 97, St143 , Sangkat Boeung
Keng Kong II, Khan Chamkarmon
Phnom Penh. Facebook: M Shop
Line: MOUYKIMLIM
Tel: 017 955 518

C Dr. FASHION

CHN FDesign

#74,st163,sangkat toul tom poung II
near in front Toul tom poung market
about 40m, Phnom Pen, Phnum Penh
081 676 222

A B C



# CONFIDENCE"
# IS THE ABILITY
# TO FEEL BEAUTIFUL

PHOTO: SEM
STYLISH: LAY SOKON




នាងខ្ញុំ RYA
កម្មវិធី
ផ្សាយបន្តផ្ទាល់នៅលើកញ្ចក់ទូរទស្សន៍ក្នុងពេលឆាប់ៗនេះ
NEW TALK SHOW
COMING SOON

# ក្ដឹប ឌីជេវ័យក្មេងកម្ពុជា
## ក្រមិចក្រមើម រប៉ិលរប៉ូចប្លែកពីគេ



ក្ដឹប ជាឌីជេ វ័យក្មេងល្បីឈ្មោះម្នាក់របស់កម្ពុជា មានចរិតក្រមិចក្រមើម រប៉ិលរប៉ូច ប៉ុន្តែអត្តចរិត និងកាយវិការខាងក្រៅគួរឱ្យចង់រាប់អាន។

ជួបជាមួយ Sabay ឌីជេ ក្ដឹប បាននិយាយថា ចរិតក្រមិចក្រមើម និងរប៉ិលរប៉ូចនេះ គឺកើតឡើងតាំងពីធម្មជាតិមកម្ល៉េះ មិនមែនទើបតែលេចរូបរាងនាពេលថ្មីៗឡើយ។

លោកបញ្ជាក់ថា៖"តាំងពីតូចមកម្ល៉េះបង អារឿងរប៉ិលរប៉ូច ចូលចិត្តធ្វើអ្វីៗប្លែកពីគេហ្នឹង"។

ទោះជាយ៉ាងណាក៏ដោយឌីជេ ក្ដឹប អះអាងថា អត្តចរិតខាងលើកើតឡើងតែក្នុងរង្វង់សិល្បៈ និងបទចម្រៀងលោកបានតាក់តែងប៉ុណ្ណោះ ពោលគឺអត្តចរិតបែបអំពើល្អ។ ដោយឡែក អត្តចរិតបែបអំពើអបាយមុខ លោកមិនដែលប្រព្រឹត្តឡើយ។

ឌីជេ ក្ដឹប បន្តថា ទោះជាទៅថ្ងៃមុខវ័យរបស់ខ្លួនជ្រេជាងមុនក្តី តែការចូលចិត្តធ្វើអ្វីប្លែកៗ ខុសពីគេតាមរយៈកាយវិការក្រមិចក្រមើម និងរប៉ិលរប៉ូចរបស់ខ្លួនមិនប្រែប្រួលនោះទេ។

ទន្ទឹមនឹងការអះអាងអាកប្បកិរិយាពីធម្មជាតិមិនអាចប្រែប្រួលបាន ឌីជេរូបនេះ បានចេញបើកផលិតកម្មថ្មីផ្ទាល់ខ្លួន ដោយផលិតតែចម្រៀងថ្មីសុទ្ធសាធមិនចម្លងពីបរទេសគឺផលិតកម្ម Camtrax Music។

តាមរយៈការបង្កើត ក៏ដូចជាផលិតចម្រៀងថ្មីៗ ឌីជេ ក្ដឹប មិនសូវរំពឹងខ្ពស់នោះទេក្នុងការលក់ CD, VCD Original លើទីផ្សារកម្ពុជា។ មិនសូវរំពឹងដោយសារតែអ្នកគាំទ្រមិនសូវឱ្យតម្លៃ និងចូលចិត្តស្តាប់ចម្រៀង Original ។

យ៉ាងណាក៏ដោយលោកបានរំពឹងខ្ពស់ថានឹងទទួលបានជោគជ័យតាមរយៈការលក់ CD, VCD Original នៅលើ Ituns Store ។

ម្យ៉ាងទៀតការខ្នះខ្នែងបង្កើតផលិតកម្មផ្ទាល់ខ្លួន ក៏ដូចជាផលិតចម្រៀងថ្មីៗ គឺដើម្បីត្រៀមសមាហរណកម្មអាស៊ាន ២០១៥ខាងមុខ។

លោកចង់បង្ហាញប្រាប់បណ្តាប្រទេសក្នុងតំបន់អាស៊ានថា អ្នកនិពន្ធកម្ពុជា ក៏មានសមត្ថភាពផលិតចម្រៀងថ្មី មិនចម្លងពីនរណាម្នាក់បានល្អ មិនចាញ់ពួកគេនោះទេ។

ក្ដឹប ជាឌីជេល្បីឈ្មោះម្នាក់ក្នុងប្រទេស កម្ពុជា ធៀបនឹងឌីជេដទៃទៀតកំពុងតែមានទីផ្សារ។ លោកតែងតែមានបទចម្រៀងថ្មីជាហូរហែចេញលក់លើទីផ្សារ និងទទួលបានការគាំទ្រជាច្រើនពីទស្សនិកជន។ ក្រៅតែពីការច្រៀងលោកក៏ជាតារាសម្តែងល្បីម្នាក់ផងដែរ ដោយលោកធ្លាប់ថតខ្សែភាពយន្តជាច្រើនដាក់បញ្ចាំងលើទីផ្សារ៕

អត្ថបទ៖ អ៊ឹង សុឡា





# ក្រុមអ្នកចម្រៀងRAP ថ្មី
# KHMER PRIDE

ឈ្មោះ ៖ កៅ ពន្លឺ / ២១ឆ្នាំ

ការសិក្សា៖ វិទ្យាស្ថានភាសាបរទេស ឆ្នាំទី៤

មុខងារក្នុងក្រុម៖ ប្រធានក្រុម & Rapper

facebook : Khmer Pride

**Sabay Magz: សូមជួយរៀបរាប់អំពី Khmer Pride**
**ពន្លឺ៖** Khmer Pride ជាក្រុមយុវជនដែលខ្ញុំបង្កើតឡើងដើម្បីអោយយុវវ័យដែលមានចំណាប់អារម្មណ៍ខាងផ្នែកសិល្បៈអាចជួបជុំគ្នាបញ្ចេញសមត្ថភាពនិងជួយគ្នាបង្វឹកសមត្ថភាពទាំងនោះទៅវិញទៅមក។បច្ចុប្បន្ននេះយើងមានសមាជិក៤រូប គឺ សុផលឫទ្ធ វិសាល ឆាយនិងរូបខ្ញុំផ្ទាល់ដែលពួកយើងសុទ្ធតែជាrapperទាំងអស់។ គោលបំណងរបស់Khmer Pride មិនមែនថាចង់ល្បីល្បាញជាតារាអីទេ។ ប្រសិនបើសមាជិកយើងគាត់ចង់ចាប់យកសិល្បៈជាអាជីពឬគ្រាន់តែយកជាចំណូលចិត្តធ្វើពេលទំនេរគឺសេរីតាមចិត្តពួកគាត់។ ចម្បងបំផុតនោះគឺថ្ងៃអនាគតចង់ពង្រីកវាអោយក្លាយជាផលិតកម្មមួយដែលយុវវ័យអាចបញ្ចេញStyleផ្ទាល់ខ្លួនហើយធ្វើអ្វីដែលគេចង់ធ្វើ។

**Sabay Magz: ក្រុម Khmer Pride មានសុទ្ធតែ rapper ។ហេតុអ្វីបានជា ពន្លឺមានចំណាប់អារម្មណ៍ពិសេសលើប្រភេទចម្រៀង rap?**
ពន្លឺ៖ ខ្ញុំចូលចិត្តវាតាំងពីក្មេង។តាំងពីនៅវិទ្យាល័យ ខ្ញុំជាសមាជិកក្រុម SPM ដែលពេលទំនេរយើងតែងតែហាត់សមរាំច្រៀងផ្សេងៗហើយពេលនោះខ្ញុំចាប់ផ្តើមចាប់អារម្មណខាងវិស័យសិល្បៈជាពិសេស។ ដល់ពេលចេញបទចម្រៀងខ្លួនឯង ការrapទទួលបានការគាំទ្រច្រើនពីប្រិយមិត្តលើប្រព័ន្ធផ្សព្វផ្សាយសង្គមនានា។ជាក់ស្តែងបទចម្រៀងពេញនិយមរបស់ Khmer Pride គឺបទ ក្តីសង្ឃឹម
អាច download បានតាម soundcloud ។

Sabay Magz: ក្រៅពីមុខងារជា rapper ពន្លឺក៏សរសេរចម្រៀង Original អោយក្រុមដែរ។តើអ្វីទៅជាឧបសគ្គក្នុងការសរសេរចម្រៀង ?
ពន្លឺ៖ ត្រង់ខ្ញុំមិនមានការសិក្សាផ្ទាល់ផ្តោតលើការសរសេរចម្រៀង។ ការសរសេរចម្រៀងពិបាកត្រង់ថាយើងមិនអាចបង្ខំបានទេ បើពេលណាមានអារម្មណទើបអាចសរសេរចេញបាន។ ដូចជាបទ ក្តីសង្ឃឹម របស់ Khmer Pride សរសេរចេញឡើងពេលដែលខ្ញុំពិបាកចិត្តពេលស្រមៃនឹកដល់ថ្ងៃអនាគត។

**Sabay Magz: ក្រៅពីសកម្មភាពសិល្បៈ ពន្លឺរវល់ច្រើននឹងការងារសង្គមផ្សេង ដូចជាចូលរួមកម្មវិធីសប្បុរសធម៌របស់អង្គការ JCI និងកម្មវិធីសប្បុរសធម៌ដល់ក្មេងកំព្រាផ្សេងៗជាច្រើនទៀត។តើការជួយអ្នកដទៃមានអត្ថន័យអ្វីពិសេសចំពោះពន្លឺ** ?
ពន្លឺ៖ ខ្ញុំសប្បាយចិត្តនឹងការចូលរួមចំណែកជួយដល់សង្គម។ដោយសារតែខ្ញុំធំឡើងនៅក្នុងស្រុកមេមុតដែលចាត់ទុកថាជាស្រុកដាច់ស្រយាលមួយដែរ ខ្ញុំអាចយល់បានពីទុក្ខលំបាកនិងការខ្វះខាតរបស់អ្នកដទៃ ហើយនេះធ្វើអោយខ្ញុំចង់ជួយគេជាងមុនទៀត។

**Sabay Magz: Khmer Pride មានគម្រោងអ្វីទេសម្រាប់ឆ្នាំថ្មីនេះ** ?
ពន្លឺ៖សម្រាប់ឆ្នាំថ្មីដែលនឹងឈានចូលមកដល់ យើងនឹងមានបទចម្រៀងគ្រោងនឹងចេញថ្មីៗ។ សូមជួយរង់ចាំស្តាប់និងផ្តល់ការគាំទ្រផង។

**Sabay Magz ៖ What exactly is Khmer Pride?**
Kao Ponleur ៖ Khmer Pride is where teens gathered and can freely show and improve their talents. Currently, we have 4 members: Sophalrith, Visal, Chhai and myself – all of which are rappers. The goal is not to make it big or for fame – that is totally up to our members whether they take it seriously as a career or as a hobby. The main goal is to expand it to an agency, where teens are welcomed to be themselves and practice their area of interest.

**Sabay Magz ៖ Khmer Pride consists of rappers. Why are you interested in rap music?**
Kao Ponleur ៖ I just like it since I was young. I was in a band, SPM, since I was in high school, where I spend my free time practicing with my friends and started to show great interest in music. And I get great response from viewers when I rap too. Our hit song, "Hope" sparks interest among social media and now it's available on for download in soundcloud.

**Sabay Magz ៖ Other than being a rapper, you also compose songs for your team. Can you tell us about the challenges of songwriting?**

Kao Ponleur I have no real composing education. I accidentally compose my first song, "Never forget me" during guitar practice and a rush of inspiration hit me as I think about my university life and how I will miss my friends after we graduate and part ways. The thing about song writing is that, we can't force it. When there's a rush of emotion, everything just flow. "Hope" , our currently released song from Khmer pride, comes from my moment of break down as I think about my future.

**Sabay Magz ៖ Beside music, you seem to busied yourself with a lot of social work, like JCI volunteer and other fund raising. What does helping others mean to you?**

Kao Ponleur ៖ It just make me happy that there is something I can contribute to the society and help other people. I grow up in a rural village myself in Memoth, so at some point I can relate their difficulties and that encourage me to help them even more. The song, Chivet Kmeng Komprea (Life of an Orphan), wholly dedicated to less fortunate kids I have encountered. They give me the inspiration to write that song and fuel my will to help them with what I have even more.

**Sabay Magz ៖ Any plans for this new year?**

Kao Ponleur ៖ Khmer Pride will release yet another song for the up coming new year. Please look forward to it.

ទំនាក់ទំនងសិល្បៈ ៖ SPM ក្រុមរាំSuper K ក្រុមចម្រៀងសប្បុរសធម៌ ដើម្បីកូនខ្មែរ និងKhmer Pride

# មណ្ឌលគីរីគ្របដណ្ដប់ដោយធម្មជាតិស្រស់បំព្រងក្នុងរដូវប្រាំង

MONDULKIRI, NATURAL EVERGREEN BEAUTY IN THE HEAT

មណ្ឌលគីរីជាខេត្តមួយស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា ហ៊ុមព័ទ្ធទៅដោយព្រៃប្រឹក្សា ប្រជុំតំបន់ភ្នំ និងទឹកជ្រោះនានា ហើយក៏ជាដែនដីមួយសម្បូរទៅដោយរ៉ែមាសនិងត្បូងដ៏ច្រើនសន្ធឹកផងដែរ។ អំណោយផលនៃអាកាសធាតុត្រជាក់ក្រោម ២០ អង្សាសេរ ដែលគ្របដណ្ដប់ខេត្តមួយនេះ បានធ្វើឱ្យមណ្ឌលគីរី ក្លាយជាតំបន់ធម្មជាតិមួយមានសម្រស់ស្រស់បំព្រងគ្មានអ្វីប្រៀបបាន បើធៀបនឹងខេត្តផ្សេងទៀតក្នុងរដូវប្រាំងនៅប្រទេសកម្ពុជា។

មណ្ឌលគីរីមានកន្លែងទាក់ទាញជាច្រើន តែទំព័រដំណើរកម្សាន្តទស្សនាវដ្ដី Sabay ពេលនេះសូមលើកយកទីតាំងតែ ៤ ប៉ុណ្ណោះមកបង្ហាញដល់មិត្តអ្នកអានទាំងអស់គ្នា ក្រែងលមានគម្រោងទៅលេងមណ្ឌលគីរីក្នុងខែនេះ។

## ១. ទឹកធ្លាក់សែនមនោរម្យ

តំបន់ទឹកធ្លាក់មួយនេះ ស្ថិតនៅចម្ងាយត្រឹមតែ ៥ គីឡូម៉ែត្រប៉ុណ្ណោះពីទីប្រជុំជនសែនមនោរម្យ។ នៅតាមដងផ្លូវក្រាលគ្រួសក្រហមឆ្ពោះទៅកាន់តំបន់មួយនេះ អ្នកដំណើរនឹងបានទស្សនាសម្រស់ធម្មជាតិនានា ដែលគ្របដណ្ដប់ដោយដំណាំឧស្សាហកម្មមានដូចជាកៅស៊ូ និងកាហ្វេជាដើម។ សែនមនោរម្យទឹកធ្លាក់មាន ៣ ជាន់។ ជាន់ទី១ ទឹកធ្លាក់ដូចជាយឺតៗបន្តិច ហើយកម្ពស់ទឹកធ្លាក់មានកម្ពស់ ១ ម៉ែត្រ ចំណែកឯជាន់ទី ២ ទឹកហូររៀងលឿនបន្តិច ព្រោះកម្ពស់ទឹកធ្លាក់គឺប្រហែលជា ៧ ទៅ ៩ ម៉ែត្រ ហើយជាន់ទី ៣ គឺស្ថិតចម្ងាយ ១ គីឡូម៉ែត្រពីជាន់ទី ២ មានកម្ពស់ទឹកធ្លាក់ត្រឹមតែ ១ ម៉ែត្រកន្លះតែប៉ុណ្ណោះ។

## ២. បោះតង់លើភ្នំ

ខេត្តមណ្ឌលគីរីចាត់ទុកថាជាខេត្តមួយដែលពោរពេញដោយទេសភាពស្រស់ត្រកាលដោយហ៊ុមព័ទ្ធដោយព្រៃក្រាស់ និងកូនភ្នំតូចធំជាច្រើន។កំឡុងខែត្រជាក់ គឺចាប់ពីខែវិច្ឆិកាដល់ខែកុម្ភៈ សីតុណ្ហភាពអាចធ្លាក់ដល់ក្រោម២០អង្សាសេ ដែលជាអាកាសធាតុត្រជាក់ល្មមសម្រាប់ការបោះតង់លើកូនភ្នំ។ អ្នកដំណើរត្រូវនាំគ្នាដើរឡើងទៅលើកូនភ្នំ ប្រសិនបើចង់សាកល្បងបទពិសោធន៍កម្សាន្តមួយនេះ។ យ៉ាងណាក៏ដោយ អ្នកត្រូវមានសម្ភារៈខ្លួនឯង ព្រោះនៅទីនោះភាគច្រើនមិនសូវមានក្រុមហ៊ុនរៀបចំសេវាកម្សាន្តបោះតង់ឡើយ។

## ៣. ទឹកជ្រោះប៊ូស្រា

ទឹកជ្រោះមាន ៣ជាន់ដូចនឹងទឹកធ្លាក់សែនមនោរម្យដែរ តែជាន់នីមួយៗមានកម្ពស់ខ្ពស់ជាងទឹកធ្លាក់សែនមនោរម្យ។ ជាន់ទីមួយមានកម្ពស់ពី៨ទៅ១២ម៉ែត្រ ជាន់ទីពីរមានកម្ពស់ពី១៥ទៅ២០ម៉ែត្រនិងចំណែកឯជាន់ទីបីពុំទាន់មាននរណាទៅដល់នៅឡើយដោយមានព្រៃក្រាស់ពេកនិងផ្លូវមិនទាន់ទ្រួសត្រាយនៅឡើយទេ។

## ៤. ផ្សារមណ្ឌលគីរី

អ្នកពិតជាប្លែកភ្នែកពេលចូលទៅដល់ផ្សារមណ្ឌលគីរី! ការរៀបចំតូបលក់តវ៉ាន់និងម្ហូបអាហារមើលទៅដូចជាប្លែកបន្តិច បើធៀបនឹងផ្សារក្នុងស្រុកផ្សេងៗ ព្រោះនៅទៅនោះអ្នកនឹងបានជួបជនជាតិភាគតិចជាច្រើន ដែលមកលក់ដូរក្នុងផ្សារនេះ។ អ្វីដែលអ្នកដំណើរទៅផ្សារមួយនេះ គឺដើម្បីទស្សនាសិប្បកម្មវត្ថុអនុស្សាវរីយ និងវប្បធម៌ជនជាតិខ្មែរភាគតិច សំលៀកបំពាក់ មុខម្ហូបនិងផលិតផលផ្សេងៗប្រចាំខេត្តមណ្ឌលគីរី។

អត្ថបទ៖ រ៉ូលីន









Located in eastern Cambodia, Mondulkiri is surrounded with jungles, hillside, waterfalls and other natural resources such as gold and diamonds. Despite the dry season in Cambodia, Mondolkiri temperature may drop as low as 20 degree Celsius, making it the evergreen natural beauty unlike any other part of the country.

Mondolkiri has many tourist attractions but Sabay Magz would like to present only 4 sites in case our readers plan to go there. So let's check it out together!

**1. SEN MONOROM WATERFALL**

Stand at 5km from the populous town of Sen Monorom. Along the road, you'll be greeted with the natural beautiful view of rubber and coffee plantations. The waterfall itself has 3 stages. The first stage runs slowly within the height of 1 meter. Stage 2, waterfall flows faster since it drops from the height of 7-9metres. The 3rd stage is around 1 km further from the 2nd stage and falls 1.5 meters height.

**2. CAMPING ON THE HILLTOP**

Monodolkiri is blessed with surrounded thick forest and mountains. During the cool season, from November to February, the temperature drop to 20 degree Celsius – perfect for camping! Travelers need to climb up the mountain to do so and it's recommended to bring your own camping equipments as services are hard to come by.

**3. BU SRA WATERFALL**

Like Sen Monorom, Bu Sra Waterfall is also divided into 3 stages. Stage 1 is about 8-12 metres high, stage 2 is 15-20 high, and the stage 3 is still left unexplored as transportation falls short and the forest is too thick to get through.

**4. MONDULKIRI MARKET**

You'll be in for a surprise when you get there! Products and foods are a bit different as you encounter Khmer ethnicity group. Usually travelers go there to see souvenir handicrafts and culture of ethics people – their clothes, foods, and other products of Mondulkiri.

## SONY ALPHA 7ii

Sony Alpha 7II ជាកាំម៉េរ៉ាដែលមានភ្ជាប់ជាមួយ IBIS (in body image stabilization)មានន័យថាវាមាន stabilizer ស្រាប់ក្នុងកាំម៉េរ៉ា អាចរក្សាលំនឹងបានមិនថាមានរំញ័រប្រភេទណាក៏ថតទាំងរូបភាពនិងវីដេអូច្បាស់ល្អ។ A7 II មានបំពាក់ជាមួយ 24.3 megapixel full-frame និងមាន Auto focus speed និង Auto exposure ប្រសើរជាងមុនដោយអាចចាប់បានរូបភាពកំពុងមានចលនារហ័សជាងសេរីមុនដល់ទៅ 50% និង auto-focus responsiveness 30% លឿនជាងសេរី Sony Alpha មុន។

### លក្ខណៈពិសេស៖

| | |
|---|---|
| Camera type : | Interchangeable-lens digital camera |
| Image sensor : | Type 35 mm full frame (35.8 x 23.9 mm), Exmor CMOS sensor |
| Image quality : | RAW, RAW & JPEG, JPEG Extra fine, JPEG Fine, JPEG Standard |
| Slot : | Multi slot for Memory Stick Duo / SD Memory car |
| ISO : | Still images: ISO 100-25600 |
| Other features : | Face detection |
| Shutter speed : | Still images: 1/8000 to 30 sec |
| Flash sync. speed : | 1/250 sec |
| Focus point : | 35 mm full frame: 117 points (phase-detection AF)<br>APS-C: 99 points (phase-detection AF)<br>/ 25 points (contrast-detection AF) |



sony-asia.com



getpebble.com

## PEBBLE

Pebble ជានាឡិកាឆ្លាតវៃមួយដែលផលិតដោយក្រុមហ៊ុន Pebble Technology Corporation ។ Pebble មានលក្ខណៈខុសប្លែកពី Samsung Smartwatch និង iWatch ត្រង់ថា Pebble អាចប្រើទាំងពីរ OS គឺ Android និង iOS ដូច្នេះអ្នកប្រើ Smartphone ប្រព័ន្ធប្រតិបត្តិការណ៍ទាំងពីរនេះ មិនបាច់បារម្ភឡើយ ។ ពេលភ្ជាប់ជាមួយទូរសព្ទ Pebble អាចផ្តល់សញ្ញាដល់អ្នកប្រើប្រាស់ដូចជា៖ ផ្តល់ដំណឹងពេលមានអ្នកគេផ្ញើរសារ ឬ E-mail បង្ហាញពីអ្នក Call ចូលទូរសព្ទ notifications ពីបណ្តាញទំនាក់ទំនងសង្គម និងមុខងារជាច្រើនទៀត។ ពិសេសជាងនេះ Pebble app Store មានដាក់កម្មវិធីសម្រាប់ដាក់ឲ្យទាញយកជាង ១ ពាន់កម្មវិធីឯណោះ។

តម្លៃចាប់ពី ៩៩ ដល់ ១៩៩ ដុល្លារ

### លក្ខណៈពិសេស៖

Dimensions
- Case: 52mm L × 36mm W × 11.5mm T
- Band: 22mm wide
- Weight: 38g / 1.34oz

Connectivities
- WIRELESS
- Bluetooth 4.0

Screen
- 1.26-inch, 144 × 168 pixel e-paper display
- LED backlight

Language
- English
- Character sets: Unicode, Basic Latin, And Latin-1 Supplement

Water Resistance
- 50 meter water resistance

Sensors
- 3D Accelerometer
- Compass
- light Sensor

## SONY Z3

Smartphone ជំនាន់ចុងក្រោយរបស់ Sony

ស្របពេលដែល Apple Samsung និងក្រុមទូរសព្ទជាច្រើនទៀត កំពុងតែផ្តោតទីផ្សារនៃប្រភេទទូរសព្ទអេក្រង់ធំៗ Sony ក៏បានបង្ហាញ Smartphone មួយមានឈ្មោះថា Sony Z3 មានទំហំអេក្រង់ដល់ ៥.២ អ៊ីញឯណោះ ហើយថែមទាំងអាចការពារមិនឲ្យជ្រាបទឹកក្នុងរយៈពេលយូរថែមទៀតផង។ ខាងក្រោមនេះជាលក្ខណៈពិសេសផ្សេងទៀតរបស់ Sony Z3។



### លក្ខណៈពិសេស៖

Screen
- 5.2 Inch , 1920 x 1080

Dimensions
- 146 x 72 x 7.3 mm ( 5.75 x 2.83 X 0.29 in )
- Weight: 152g

Camera
- កាមេរ៉ាក្រោយ៖ 20.7 មេហ្គាភិចសែល , 5248 x 3936 pixels, auto-focus , LED Flash
- កាមេរ៉ាមុខ៖ 2.2 មេហ្គាភិចសែល 1080p@30fps
- វីដេអូ៖ 2160p@30fps, 1080p@60fps, 720p@120fps, HDR

Features
- ប្រព័ន្ធប្រតិបត្តិការណ៍៖ Android OS, v4.44 ( Kitkat)
- Chipset ៖ Qualcomm MSM8974AC Snapdragon 801
- CPU ៖ Quad-Core 2.5 GHz Krait 400
- Sensors ៖ Accelerometer , gyro , proximity , compass , barometer
- Internal storage: 32GB microSD storage support up to 128GB
- តម្លៃប្រហាក់ប្រហែល៖ ៦៥០ ដុល្លារអាមេរិក

# APPS OF THE MONTH

F A S H I O N E D I T I O N

POLY VORE





ជាកម្មវិធីដែលអ្នកអាចជ្រើសរើសអាវ ខោ គ្រឿងអលង្ការ ផ្សេងៗពីហាងល្បីៗយកមកតម្រៀបម៉ូតបញ្ចូលគ្នាក្លាយជា Collection ផ្ទាល់ខ្លួន។កម្មវិធីនេះសាកសមបំផុតសម្រាប់អនាគតអ្នកច្នៃម៉ូត។

Get inspired! Polyvore allows users to personalize tops, jeans and accessories and compile them to publish their own collection. Basically, this is a dream come true for starter stylish!
Compatibility: iOS and Android





The Hunt
អ្នកប្រហែលធ្លាប់ជួបប្រទះហើយ ពេលខ្លះឃើញអ្នកដទៃពាក់ម៉ូតខោអាវឡូយៗតែមិនដឹងគេទិញពីណាមក។ក្នុងកម្មវិធី The Hunt អ្នកអាចថតរូបសំលៀកបំពាក់ ម៉ូតដែលអ្នកស្រលាញ់ហើយមិត្តអ្នកប្រើកម្មវិធីនេះដូចគ្នានិងប្រាប់ពីតម្លៃនិងហាងដែលមានលក់របស់នោះ។

Have you ever spotted a killer outfit but don't know where to find it? Look no further. Simply upload the picture of your WANTED outfit and the community will hunt you information of where to find it and how much.
Compatibility: iOS and Android

Pose

Shop closets, browse trends, and find what to wear this season.



Pose
បង្ហាញពីម៉ូតសំលៀកបំពាក់ផ្ទាល់ខ្លួន( street fashion ) ថ្មី ប្លែករបស់មនុស្សទូទៅដែលភាគច្រើនជាអ្នកច្នៃម៉ូតក្មេងខ្ចី។រូបអ្នកផ្ទាល់ក៏អាចថតរូបសំលៀកបំពាក់ដែលពាក់ប្រចាំថ្ងៃ ( #ootd ) ហើយអោយគេបោះឆ្នោតគាំទ្រផងដែរ។

Celebrate your individuality! Scroll down infinitely the ultimate #ootd (a.k.a outfit of the day). Pose is filled with magnificent street fashion of the hidden designer in the making.
Compatibility: iOS and Android

# DECEMBER RELEASE




**5.12.14**

**WOLVES**



**12.12.14**

**AUTOMATA**




**15.12.14**

**GOOD PEOPLE**




**18.12.14**

**ZOMBIE FIGHT CLUB**




**23.12.14**

**CALL ME BAD GIRL**

ដៅគគុក និងមិនអាចគ្រប់គ្រងខ្លួនឯងបាន Richard មិនយល់ពីកម្លាំងមហិមាដែលគេចាប់ផ្តើមមានពេលទើបនឹងពេញវ័យនេះទេ។ សំណាងល្អគេបានជួបពួកប្រភេទមនុស្សចចកដូចគ្នាហើយអាចអោយគេយល់ដឹងពីខ្លួនច្បាស់ជាងមុនតែគេជាអ្នកប្រមាញ់រកការពិតឬមាននរណាផ្សេងទៀតចាំប្រមាញ់គេ?

Aggressive, hot, uncontrollable. Richard is lost with the new inhumane power he started having as he comes of age. Meeting up with one of his kind, he set out a path to track down his family history. But as the story unfold, is he the hunter or hunted?

ក្នុងឆ្នាំ 2044 ក្នុងអនាគតកាលមានមនុស្សយន្តជំនាន់ថ្មីមួយត្រូវបានគេបង្កើតឡើងដោយបន្ថែមនូវខួរក្បាលមានមនសិការដូចមនុស្សដែរ។ ពេលដែលមនុស្សយន្តទាំងនោះចាប់ផ្តើមបះបោរសង្គ្រាមនឹងផ្ទុះឡើង។ មនុស្សអាចបង្ក្រាបគ្រឿងយន្តបាន ឬមនុស្សយន្តជាអ្នកស្តារឡើងវិញនូវភាពជាមនុស្ស?

In the year 2044, a new robotprototype was created.
It was one-of-a-kind, created with not only functional perfection but also perception similar to that of a human. As they rebels against human, we will see whether human will put a stop to the robot rebellion or robots will stop the the human from harming others and restore humanity instead.

គូស្នេហ៍មួយគូរនេះមិនដែលធ្វើអ្វីខុសទេតែពួកគេបានរកឃើញលុយទាំងសន្ទឹកចំនួនUSD120,00 ក្នុងផ្ទះ។ បន្ទាប់ពីនោះមកគេត្រូវប៉ូលិស និង ចោរ ដែលលួចលុយនោះដេញចាប់។ គេដឹងថាលុយនោះជាលុយកខ្វក់មិនល្អតែបើពួកគេជាមនុស្សល្អប្រើវាវិញនោះ...?

The Wright couple is, let's say, right. An innocent couple who found a bundle of USD 120,00 in cash in their apartment got mingle in a chaotic commotion as they are hunted down by the police and the thief at the same time. They know it's bad money, but what exactly make money bad...? The people.

មានរឿងចម្លែកមួយបានកើតឡើងហើយមនុស្សក្នុងអាគារនោះក្លាយជាខ្មោច Zombie ទាំងអស់។ Jenny ជាតួឯកដែលត្រូវប្រឈមមុខនិងមេដឹកនាំ Zombie ដ៏ឃោរឃៅដែលចាប់មនុស្សមកសម្លាប់ម្តងម្នាក់ៗ ដោយឲ្យពួកគេវាយប្រដាល់គ្នានឹងខ្មោច Zombie។

Mystery happens. A building full of people are now filled with zombies. Our lead character, Jenny, found the challenge to survive as she had to confront the vicious zombie leader, once her kind-hearted chemistry teacher, who cruelly kill people one after the other by matching up human to fight with zombies – creating the Zombie fight club.

ដើរលេងយប់ក្នុងក្លឹប ស្រវឹងមានសង្សារច្រើនរាប់មិនអស់។ តួស្រីយើងគេគិតថាគេជាស្រីមិនល្អហើយនឹងបញ្ចេញមន្តស្នេហ៍ចាប់នាយសាមុទដែលមើលទៅស្លូតៗនោះអោយបាន។ ប៉ុន្តែនាងមិនដឹងទេថាក្នុងចិត្តសាមុទមិនថានាងនិយាយយ៉ាងណាក៏មើលទៅនៅតែថានាងជាមនុស្សល្អរបស់គេដែរ។

Getting drunk, clubbing, and have tons of boyfriends beforehand, our lead character thought she's a bad girl about to hunt Samot, an innocent, trustworthy guy down. However, no matter what she seems to think of herself, to him, she's still a pretty tame good girl.


PLATINUM cineplex

ផ្លាទីនៀម ស៊ូរិយា ជាន់ទី5

BOOKING » 081/086-666-210

Google play
App Store

INTERNATIONAL DIGITAL 3D CINEMA

WWW.PLATINUMCINEPLEX.COM.KH


# MOVIE REVIEW



គំនូរជីវចលដែលអ្នកគ្រប់គ្នាចូលចិត្តនឹងចាប់បញ្ចាំងជា3D!
Doraemon ជាឆ្មាយន្តដែលធ្វើដំណើរពីអនាគតកាលហើយនាំយកមកនូវបច្ចេកវិទ្យាប្លែកៗជាច្រើនមកជាមួយវាហើយឥវ៉ាន់ទាំងអស់នោះហើយដែលតែងតែជួយមិត្តរបស់គេ Nobita រហូត។ប៉ុន្តែឥលូវ Nobita បានប្រព្រឹត្តកំហុសធ្ងន់មួយ ដែលធ្វើអោយ Doraemon ត្រូវចាកចេញ។ តើមិត្តភាពរបស់ពួកគេនឹងទៅជាយ៉ាងណា?

The manga franchise is back in 3D with its new adventure! Doraemon is actually a robot cat that traveled from the future into the current time line and brought with it many cool items that always help Nobita out of troubles. However, now that Nobita messes up and Doraemon needs to leave, what will happen to their friendship?

## STAND BY ME DORAEMON 3D

**25.12.14**

sabay/mvp

# LIVE FAST DIE YOUNG BE WILD HAVE FUN
















HAPPY!
Christmas & New Year with
Monument Books
MONUMENT TOYS
Events in December:
(only at 111, Norodom Blvd)
13th & 20th Dec 2014
Face Painting (10-11am)
Magic show (2-3pm)
14th & 21st Dec 2014
Balloon Twisting (10-11am)
Santa Photo (2-3pm)
Treasure Hunt (3-4pm)
Branches in Cambodia:
111, Norodom Blvd, Phnom Penh
AEON Mall, 1st Floor, Phnom Penh
Ta Prohm Hotel, Ground Floor, Siem Reap
Siem Reap Airport
Monument Books and Toys Cambodia


ice park
Presented by Smart
Sharpen your ice skating skills,
fun lessons that get results with Coach Judy
1st December 2014 - 7th January 2015 / Monday - Saturday from 9am to 6pm
Register Now
@ ICE PARK: AEON MALL, 4th floor
Hotline: 093 888 222
www.iceparkcambodia.com
Coach Judy
TRIPLE GOLD TEST CERTIFIED
Judy Lowrie is a Canadian Triple Gold Test Certified Figure Skating Coach. She has passed the highest figure, freestyle, and dance tests in the Skate Canada system.


SPARK & TAWANDANG MICROBREWERY
PHNOM PENH
SINCE 1999
SPARK & TAWANDANG
MICROBREWERY RESTAURANT
THE PRIDE OF PHNOM PENH
រីករាយកម្មវិធីពិសេស!!!
FREE FLOW!
សំរាប់កម្មវិធីខួបកំណើត, ជួបជុំមិត្តភ័ក្តិ, និងកម្មវិធីផ្សេងៗទៀត
ចំណាយតែ $28 / ម្នាក់ប៉ុណ្ណោះ..!!!
ជាមួយនឹងអាហារ ១០មុខ ព្រមទាំងពិសារស្រាបៀរ,
ភេសជ្ជៈកំប៉ុង និង ទឹកសុទ្ធ FREE រហូតដល់ចប់កម្មវិធីជប់លាង
● BEST BEER ● BEST FOOD ● BEST CUISIN
● BEST ENTERTAINMENT ● BEST ATMOSHERE
លោកអ្នកអាចរីករាយជាមួយនឹងការសម្តែងពិសេសៗ រួមទាំងកំប្លែងរបស់ក្រុមនាយកុយ!!

# ក្រុមខ្លាំង E-SPORTS

## ប្រចាំកម្ពុជា ទាំង ៦រកឃើញ

### លេខ ១&២ AK Online នឹងបន្តការប្រកួតជាអន្តរជាតិនៅចិន

ឆ្លងកាត់ការប្រកួតប្រជែងដ៏តានតឹង រវាងជើងខ្លាំង ១៦ក្រុម កាលពីថ្ងៃទី ២២-២៣ ខែវិច្ឆិកា កន្លងទៅ Sabay រកឃើញក្រុមខ្លាំងបំផុតប្រចាំប្រទេស ៦ក្រុម លើសេវាកម្សាន្តអនឡាញ AK Online និង Age Of Naga ប្រចាំឆ្នាំ ២០១៤នេះ។ ពិសេសបំផុតនោះគឺ ជយលាភីលេខ១ និងជើងឯករង កីឡាអេឡិចត្រូនិក AK Online នឹងបន្តភាពខ្លាំងរបស់ខ្លួន តំណាងឲ្យប្រទេសកម្ពុជា ទៅតតាំងជាមួយ ក្រុមខ្លាំងៗមកពីបណ្តាប្រទេសជាច្រើនទៀត ក្នុងកម្មវិធី MATIC ២០១៥ ដែលនឹងរៀបចំឡើងនៅប្រទេសចិន។

ការជម្រុះយកតែ ៣ក្រុម សម្រាប់កីឡាអេឡិចត្រូនិក Age of Naga និង ៣ ក្រុមសម្រាប់សេវាកម្សាន្ត AK Online ពីជើងខ្លាំងសរុប ១៦ ក្រុមមកពី ៤ ខេត្ត/ក្រុង រាជធានីផ្សេងគ្នារួមមាន ខេត្តព្រះសីហនុ បាត់ដំបង សៀមរាប និងម្ចាស់ផ្ទះរាជធានីភ្នំពេញនេះធ្វើឡើង រយៈពេល ២ថ្ងៃ គឺចាប់ផ្តើមតាំងពីម៉ោង ៨ព្រឹក កាលពីថ្ងៃសៅរ៍ អាទិត្យ ទី ២២-២៣ វិច្ឆិកា នៅរោងមហោស្រពចេនឡា កន្លងទៅ។

Cambodian Cyber Championships ឬ CCC ២០១៤ ជាកម្មវិធីប្រកួតប្រជែងសេវាកម្សាន្តអនឡាញ ប្រចាំឆ្នាំ ដែលរៀបចំឡើងដោយក្រុមហ៊ុន Sabay ក្នុងគោលដៅរកឲ្យឃើញក្រុមខ្លាំងបំផុតប្រចាំប្រទេស លើសង្គ្រាមកីឡាអេឡិចត្រូនិកដ៏រន្ធត់បង្កប់ទៅដោយយុទ្ធសាស្ត្រ ភាពអត់ធ្មត់ ប្រាជ្ញាវាងវៃ រហ័សរហួន ស្មារតីក្រុម ប្រាក់រង្វាន់លើកទឹកចិត្តទៀតជាច្រើន បូករួមទាំងឱកាសទៅបញ្ចេញសមត្ថភាព ប្រជែងដណ្តើមពានអន្តរជាតិទៀតផង។



ក្រុមលេខ ១ Secret



ក្រុមលេខ ២ NeverCare



ក្រុមលេខ ៣ DengSrabHai

### សេវាកម្សាន្ត Age Of Naga

| ក្រុមលេខ ១ YouKnowTHeLOser៖ ទទួលបានពានរង្វាន់កិត្តិយសចំនួន ១ មេដាយកិត្តិយស៥ ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក រួមទាំង ៤ ម៉ឺន Sabay Gold។
| ក្រុមលេខ ២ ZuMiz168៖ ទទួលបានមេដាយកិត្តិយស ៥ ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក រួមទាំង ៤ ម៉ឺន Sabay Gold។
| ក្រុមលេខ ៣ Nofuture476៖ ទទួលបានមេដាយកិត្តិយស ៥ និង ២ ម៉ឺន Sabay Gold ។

### សេវាកម្សាន្ត AK Online

| ក្រុមលេខ ១ Secret ៖ ទទួលបានពានរង្វាន់កិត្តិយស ១ មេដាយកិត្តិយស ៥ ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក រួមទាំង ៤ ម៉ឺន Sabay Gold។
| ក្រុមលេខ ២ NeverCare៖ ទទួលបានទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក និង ៤ ម៉ឺន Sabay Gold។
| ក្រុមលេខ ៣ DengSrabHai៖ ទទួលបានមេដាយកិត្តិយស ៥ និង ២ ម៉ឺន Sabay Gold។

ក្រៅពីរង្វាន់ដែលទទួលបានខាងលើ ជយលាភីសេវាកម្សាន្ត AK Online ក្រុម Secret និងក្រុម NeverCare នឹងតំណាងឲ្យកម្ពុជាក្នុងការចូលរួមប្រកួតស្វែងរកជើងខ្លាំងកីឡាអេឡិចត្រូនិក E-Sports អន្តរជាតិ ផ្នែកសេវាកម្សាន្ត AK Online ក្នុងកម្មវិធី MATIC ២០១៥ ជាមួយ ៦ ប្រទេសផ្សេងទៀតរួមមាន៖ សិង្ហបុរី ម៉ាឡេស៊ី ថៃ តៃវ៉ាន់ ឥណ្ឌូណេស៊ី និងម្ចាស់ផ្ទះប្រទេសចិន។

កាន់តែពិសេសសម្រាប់ MATIC ឆ្នាំនេះ សេវាកម្សាន្ត AK Online បានផ្តល់កាដូពិសេសដល់អ្នកកម្សាន្តមួយក្រុមផ្សេងទៀតឲ្យមាន ឱកាសចូលរួមប្រកួតក្នុងព្រឹត្តិការណ៍ប្រកួតអន្តរជាតិ MATIC 2015 ជាមួយជើងខ្លាំងទាំង ២ ក្រុមខាងលើនេះផងដែរ ដែលមួយក្រុមនោះគឺជាសមាជិក Clan ដែលទទួលបានពិន្ទុ League ខ្ពស់ជាងគេប្រចាំ Team Challenge ក្នុងសប្តាហ៍ទី ៤ នៃខែវិច្ឆិកា (ពីថ្ងៃច័ន្ទទី ២៤ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា)។



E-SPORTS sabay.com

sabay

CAMBODIAN CYBER CHAMPIONSHIPS 2014




# THAILAND INTERNATIONAL MOTOR EXPO 2014

កាលពីថ្ងៃទី ២៩ ខែវិច្ឆិកាឆ្នាំ ២០១៤ កន្លងទៅនេះ ប្រទេសថៃបានបើកសម្ពោធជាផ្លូវការនូវពិព័រណ៍រថយន្តលំដាប់ពិភពលោក Thailand International Motor Expo 2014 របស់ខ្លួនក្រោមប្រធានបទ«អាស៊ានឆ្ពោះទៅមុខជាមួយគ្នា» « Moving Forward together » ស្ថិតក្នុងគោលដៅពង្រឹង និងបង្កើនការនាំចេញរថយន្តនៃប្រទេសខ្លួន ទៅកាន់ពិភពលោក ក៏ដូចជាតំបន់អាស៊ានទាំងមូល។

លោក Nopparat Maythaveekulchai ប្រធានការិយាល័យរៀបចំពិព័រណ៍និងសន្និបាត ( Thailand Convention and Exhibition Bureau ) បានថ្លែងក្នុងពិព័រណ៍រថយន្តលំដាប់ពិភពលោកថា TCEB ជាការិយាល័យសាធារណៈមួយដែលស្ថិតក្រោមការជ្រោមជ្រែងពីរដ្ឋាភិបាលថៃ ។ បេសកកម្ម TCEB បង្កើត ឡើងដើម្បីជួយបង្កើនសក្តានុពលដល់ឧស្សាហកម្ម MICE ពាក់ព័ន្ធនឹង ការប្រជុំ ( meetings ) អត្ថប្រយោជន៍( incentives ) ការ ធ្វើសន្និសីទ ( conferencing ) និងការរៀបចំតាំងពិព័រណ៍ ( exhibitions ) ជាពិសេសឧស្សាហកម្មយានយន្តផ្ទាល់តែម្តង។ការតាំងពិព័រណ៍អន្តរជាតិចាត់ទុកបានថាជាសកម្មភាពចម្បងមួយរបស់ MICE ដែលដើរតួយ៉ាងសំខាន់ក្នុងការជំរុញនិងអភិវឌ្ឍសេដ្ឋកិច្ចនៃវិស័យឧស្សាហកម្មតាមរយៈពាណិជ្ជកម្មនិងការវិនិយោគ។

ឧស្សាហកម្មរថយន្តថៃបច្ចុប្បន្នមានលទ្ធភាពផលិតរហូតដល់ ២ លានគ្រឿងក្នុងមួយឆ្នាំ ហើយ៥០ភាគរយត្រូវបាននាំចេញទៅកាន់ទីផ្សារបរទេស។ នៅឆ្នាំ ២០១៥ ខាងមុខនេះ ទីផ្សាររថយន្តនៅអាស៊ាន ត្រូវបានគេរំពឹងទុកថានឹងមានការកើនឡើងនៃការលក់ចេញរថយន្តលើសពី ៤,៧ លានគ្រឿង ដែលនឹងក្លាយជាទីផ្សារលំដាប់ទី ៦ លើពិភពលោក។

ក្នុងតំបន់អាស៊ាន ឥណ្ឌូណេស៊ីអាចចាត់ទុកថាជាប្រទេសដែលមានក្រុមហ៊ុនផលិតរថយន្តធំ ជាងគេទីពីរ ឯឧស្សាហកម្មផលិតរថយន្តនៅម៉ាឡេស៊ីជាក្រុមហ៊ុនផលិតធំជាងគេទីបី ដែលផលិតផលភាគច្រើនជាប្រភេទរថយន្តដឹកអ្នកដំណើរ។ ហ្វីលីពីន ទោះបីជាការផលិតរថយន្តមានដល់ទៅ ១ លានគ្រឿងក្នុងមួយឆ្នាំ ប៉ុន្តែប្រទេសនេះ បានជាប់លំដាប់ជាក្រុមហ៊ុនផលិតគ្រឿងបន្លាស់រថយន្តដ៏សំខាន់មួយ ក្នុងអាស៊ាន។ ស្ថិតក្រោមការរៀបចំ និងបង្កើតគោលដៅវែងឆ្ងាយ តាមរយៈ Motor Expo 2014 នេះ ប្រទេសថៃនឹងក្លាយជាមជ្ឈមណ្ឌលពិព័រណ៍រថយន្តលំដាប់ពិភពលោកដ៏ធំមួយក្នុងតំបន់អាស៊ាន។

លោក Kwanchai Paphaphong ប្រធានរៀបចំ Thailand International Motor Expo 2014 បានលើកឡើងថា៖ " យើងមានកិត្តិយសខ្លាំងណាស់ដែលមានការចូលរួម និងផ្តល់ការជ្រោមជ្រែងពីរដ្ឋាភិបាលរហូតដល់ទទួលបានការទទួលស្គាល់ថាការ MOTOR EXPO ជាពិព័រណ៍រថយន្តមួយមានលក្ខណៈស្តង់ដារលំដាប់អន្តរជាតិបែបនេះ ”។ បន្ថែមពីនេះ តាំងពីឆ្នាំ ២០១២ សមាគមឧស្សាហកម្មពិព័រណ៏ពិភពលោកThe Global Association of the Exhibition Industry ឬក៏ UFI (UNION DES FOIRES INTERNATIONALES ) ក៏បានទទួលស្គាល់ដែរថាការរៀបចំពិព័រណ៍មានលក្ខណៈស្តង់ដារត្រឹមត្រូវ ដែលមូលហេតុមួយផ្សេងទៀតជំរុញឱ្យ MOTOR EXPO ឆ្ពោះមកដល់ស្តង់ដារលំដាប់ពិភពលោកដូចបច្ចុប្បន្ន៕

Thailand international motor exhibition launched this November 29th 2014 under the title of ASEAN Moving Forward Together with the objectives of maintaining and strengthening motor export worldwide as well as other ASEAN nations.

Mr. Nopparat Maythaveekulchai, President of the Thailand Convention and Exhibition Bureau, said, "TCEB is a public organization under the Prime Minister's Office, established with a mission to support, promote and develop the potential of Thailand's MICE industry. An international trade show is considered to be a MICE activity that plays a key role in driving the economy and developing the industrial sector of Thailand through trade and investment."

Thailand motor industry produce up to 2 million engines per year, 50% of which are exported. In 2015, ASEAN motor market is expected to increase, reaching at least over 4.7million engines, making it the 6th biggest car market of the world.



Among the ASEAN nations, Indonesia is considered the 2nd biggest car producer, and Malaysia coming 3rd with its productions mostly consists of vehicles for traveling. Philippine, though produce up to 1 million cars per year, is known as one of the most important the car parts providers of ASEAN. Under the organization and long-term vision of Motor Expo 2014, Thailand will be the center of international car exhibition in ASEAN.

Kwanchai Paphatphong, President of Inter-Media Consultant Co., Ltd. and Organizing Chairman of the MOTOR EXPO said, "We are deeply honoured that our event has gained trust and support from the public sector, attesting that the MOTOR EXPO is a Car Show of international standing. Besides, The Global Association of the Exhibition Industry or UFI (UNION DES FOIRES INTERNATIONALES) has given its seal of approval to the MOTOR EXPO since 2012, further assuring that the event is organized to international standards."



# TACOS ចល័តតែមួយគត់ នៅភ្នំពេញ





អាជីវកម្មចល័តលក់ភេសជ្ជៈ និងអាហារចល័តហាក់បីដូចជាកំពុងស្ទុះខ្លាំងមែនទែននៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រភេទអាជីវកម្មដែលប្រើរ៉ឺម៉កម៉ូតូ និងឡានក្នុងការផ្លាស់ប្តូរទីតាំងទាំងនោះមានដូចជា កាហ្វេ តែបៃតង ការ៉េម បបរគ្រឿង មីឆា និងគុយទាវជាដើម ។
ប្លែកពីប្រភេទអាហារដែលបានរៀបរាប់ខាងលើ ទស្សនាវដ្តី Sabay សូមបង្ហាញពីប្រភេទអាហារមកពីប្រទេសមិចស៊ិចកូមួយ ដែលទើបតែចាប់បើកដំណើរការកាលពីពេលថ្មីៗនេះ ក្នុងទីក្រុងភ្នំពេញ។ អាហារចល័តថ្មីមួយនេះមានឈ្មោះថា Tacos។

Tacos ជាប្រភេទអាហារ Fast Food មួយដែលត្រូវបានគេប្រើ Wrap ( បន្ទះសម្រាប់ខ្ចប់Taco ផ្សំចេញពីម្សៅ ) ដើម្បីខ្ចប់គ្រឿងផ្សំផ្សេងៗមានដូចជា បន្លែ ដំឡូង និងសាច់ច្រើនប្រភេទ។ សាច់ដែលត្រូវប្រើគឺ សាច់ជ្រូក មាន់ និងសាច់គោ។ លោក Justin Landis ម្ចាស់អាជីវកម្ម Annebella's Hot Tacos ចល័តមួយនេះ បានប្រាប់ពីហេតុផលដែលនាំឱ្យលោកសម្រេចចិត្តបើកអាជីវកម្ម Tacos នេះថា ដោយសារលោកចង់ផ្តល់អាហារ Fast Food មួយប្រភេទ មិនត្រឹមតែផ្តល់សុខភាពល្អដល់អ្នកចូលចិត្ត Fast Food នោះទេ គឺថែមទាំងចំណេញពេលវេលាថែមទៀតផង បើសិនជាអ្នកទាំងនោះគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការចម្អិនម្ហូប។

លោកបញ្ជាក់បន្ថែមពីអាហារមួយនេះថែមទៀតថា Tacos ត្រូវបានគេនិយមទូទាំងសាកលលោក ជាពិសេសប្រជាជននៅបណ្តាប្រទេសលោកខាងលិច។ តែក្រោយពេល Tacos បង្ហាញវត្តមានបានមួយរយៈកន្លងមក លោកសង្កេតឃើញថា យុវវខ្មែរក៏ចូលចិត្ត Tacos ដូចជនបរទេសដែរ ព្រោះឱ្យ

តែពេលឡានAnnebella's Hot Tacos ចាប់ផ្តើមចេញដំណើរម្តងៗ ភ្ញៀវមកទិញភាគច្រើនជាជនជាតិខ្មែរ។ Annebella's Hot Tacosមិនត្រឹមតែបម្រើសេវាកម្មលក់អាហារចល័តប៉ុណ្ណោះទេ ថែមទាំងមានទទួលធ្វើម្ហូបតាមកម្មវិធីនានាទៀតផង។

សព្វថ្ងៃនេះ Annebella's Hot Tacosបើកដំណើរការត្រឹមតែ២ទៅ៣ថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍។ លោក Justin Landis ប្រាប់ពីមូលហេតុនេះថា ដោយសារការត្រៀមរៀបចំចម្អិន Tacosត្រូវចំណាយពេលយូរ ហើយបុគ្គលិកក៏មិនទាន់គ្រប់ទៀត ដូច្នេះនេះជាអ្វីដែលលោកអាចធ្វើបាន។ " Tacos ដែលខ្ញុំបានត្រៀមទាំងអស់ហ្នឹង គឺលក់មិនដែលសល់ទេ។ និយាយរួមទៅ Tacosពេញនិយមណាស់ ហើយគម្រោងសម្រាប់ពង្រីកអាជីវកម្មនេះខ្ញុំបានគិតបណ្តើរៗហើយ។ ឆាប់ៗនេះ ឡានចល័តមួយទៀតពី Annabella's Hot Tacos នឹងរត់ពេញក្រុងភ្នំពេញហើយ!" ។ Justin បញ្ជាក់។

ឡានរបស់ Annabella's Hot Tacos ត្រូវបានរំលេចដោយគំនូរ Gravity ពីវិចិត្រករដ៏ល្បីពីររូប គឺ កញ្ញា Lisa Mam និងលោកPreapTarr។ ដូច្នេះឡាន Annabella's Hot Tacos គ្រាន់តែក្រឡេកគឺស្គាល់ហើយ ព្រោះមានតែមួយគត់នៅទីក្រុងភ្នំពេញ។ ព័ត៌មានបន្ថែមពាក់ព័ន្ធនឹង Annabella's Hot Tacos មិត្តអ្នកអាចអាចរកបាននៅទីនេះ www.facebook.com/pages/Annabellas-Hot-Tacos៕

អត្ថបទ៖ រ៉ូលីន

**TACOS PRICE :**
2 – 4$
3 – 5$





ក្រោយមានលំហូរម៉ាករថយន្តល្បីៗ មកទីផ្សារប្រទេសកម្ពុជា MG 6 រថយន្តរបស់អង់គ្លេស ក៏បានបង្ហាញខ្លួនគួរឱ្យភ្ញាក់ផ្អើលដែរ ក្នុងពិព័រណ៍រថយន្ត Car Auto Show 2014 នៅកោះពេជ្រ កាលពីពេលថ្មីៗនេះ។ វត្តមានរបស់ MG6 បានធ្វើឱ្យអ្នកទស្សនាជាច្រើនចាប់អារម្មណ៍ ប៉ុន្តែទោះបីជាយ៉ាងណា ប្រិយមិត្តមួយចំនួន ប្រហែលមិនទាន់ដឹង លក្ខណៈសម្បត្តិរបស់រថយន្តទំនើបមួយនេះទេ។ ដូច្នេះសូមតាមដានជាមួយទស្សនាវដ្ដី Sabay ដូចខាងក្រោម៖

# MG6 រថយន្តស៊េរីថ្មីរបស់អង់គ្លេស មកដល់កម្ពុជាហើយ !

## +ផ្នែកម៉ាស៊ីន

@ ប្រភេទI.8DVVTទំហំ ១៧៩៦សេសេ
-កម្លាំងថាមពល ៩៨គីឡូវ៉ាត់
-កម្លាំងរមួល ១៧0ញ៉ូតុន-ម៉ែត្រ
-ចង្កឹះលេខអូតូនិងលេខដៃ ៥លេខ
-ល្បឿនអតិបរមា ១៨៨គ.ម/ម៉.
@ ប្រភេទ I.8T ទំហំ ១៧៩៦សេសេ
-កម្លាំងថាមពល ១១៨គីឡូវ៉ាត់
-កម្លាំងរមួល ២១៥ញ៉ូតុន-ម៉ែត្រ
-ចង្កឹះលេខអូតូនិងលេខដៃ ៥លេខ
-ល្បឿនអតិបរមា ២០៥ គ.ម/ម៉.

## +ផ្នែកសុវត្ថិភាព

-ប្រព័ន្ធហ្វ្រាំងជំនួយ ABS
-ប្រព័ន្ធចែកចាយសម្ពាធហ្វ្រាំងអេឡិចត្រូនិក EBD
-ប្រព័ន្ធហ្វ្រាំងជំនួយ BA
-ប្រព័ន្ធប្រាប់ពីគ្រោះថ្នាក់ ( Overspeed Warning )ពេលបើកបរហួសល្បឿនកំណត់
-ខ្សែក្រវាត់សុវត្ថិភាព និងកៅអី ISOFIXសម្រាប់ក្មេង
-ពោងសុវត្ថិភាពការពារអ្នកបើកបរនិងអ្នកដំណើរ
-ប្រព័ន្ធគ្រប់គ្រងល្បឿនស្វ័យប្រវត្តិ
-គេឡេបញ្ឆេះម៉ាស៊ីនរថយន្ត
-ប្រព័ន្ធ Sensor បង្ហាញពីការចូលចតផ្នែកខាងក្រោយ

## +ឧបករណ៍ផ្សេងៗ

រួមមាន វិទ្យុ , CD Player, រន្ធ USB, ម៉ាស៊ីនត្រជាក់, កៅអីស្រោមស្បែក ,កៅអីស្រោបសាច់កំណាត់

## +ពណ៌៖

Birmingham Orange, Black Opal, Manchester Red, Lake Blue, Misty Blue, Misty Grey, Champagne, Scottish Silver, Summit White។

## +ផ្នែកតួគ្រោង

បណ្ដោយ Xទទឹង Xកម្ពស់៖ ៤៦៥៣ស.មX ១៨២៧ស.មX ១៤៧៨ស.ម គម្លាតកង់មុខក្រោយ ២៧០៥ស.ម និងចំណុះធុងប្រេង ៦២លីត្រ៕

អត្ថបទ៖ អ៊ុំ សុភក្តិ




















www.facebook.com/jessyjuicekh
jessyjuice168
#12 Sothea Ros Blvd, Chamkarmon District, Tonlebasak Quater Phnom Penh, 12203
012388112

**Franchisee Contact Number :**
**012 255 804**


# MAKE UP TUTORIAL

(by Janny Victory Salon)


Janny Victory Salon

No.105, street 63, Sangkat
Boeung Raing , Khan Doun
Penh, Phnom Penh, Cambodia
HP: 092 22 9999 / 012 56 66 56


BEAUTY

1 ចាប់ផ្តើមដោយប្រើម្សៅទ្រនាប់ផាត់អោយម៉ត់ពេញផ្ទៃមុខ ប្រសិនបើអ្នកមានស្នាមមុន ស្នាមផ្សេងៗលើមុខ ឬ ស្នាមដក់ក្រោមភ្នែក យក concealer មកលាបពីលើស្នាមទាំងនោះដើម្បីទទួលបានផ្ទៃមុខស្រស់ស្អាតគ្មានស្នាម។

1. Started off with a clean face, apply foundation to accomplish a blemish free face. If you have any mark/scar or puffy bags under your eyes, use a concealer and tap it on the affected area gently.

2 **ការផាត់ភ្នែក** ៖ ស្រមោលភ្នែកអាចផាត់អោយភ្នែកអ្នកមើលទៅ ធំស្អាតជាងមុនដោយផាត់ភ្នែកនិងគូរ eye liner ចាប់ពីចំណុច85% ពីគល់ភ្នែក។

2. Eye Shadow: Don't try adding an eye liner wing at the end of your eyelid. To create depth and shadow your eyes correctly, start lifting your eye shadows and eye liner at a 85% point to open up your eyes more naturally.

3 **ចិញ្ចើមស្អាត៖** ប្រើ concealer គូសក្រោមចិញ្ចើមដើម្បីអោយចេញរាងចិញ្ចើមច្បាស់ល្អ រួចយកជក់និងម្សៅផាត់ភ្នែកអោយត្រូវនឹងពណ៌ចិញ្ចើមអ្នកមកផាត់លើចិញ្ចើម ធ្វើអោយចិញ្ចើមមើលទៅស្អាតបែបធម្មជាតិជាងបើប្រៀបធៀបនឹងការគូរខ្មៅដៃយកតែម្តង។

3. Perfectly arched brow: use a concealer to define your brow shape and eyeshadow and brush to fill in your brow instead of using a traditional eyebrow liner would give you a more realistic brow line.

4 **ការផាត់ថ្ពាល់៖** ផាត់ចេញពីថ្ពាល់ខាងក្នុងចេញមកកណ្តាលថ្ពាល់ រួចមកម្សៅផាត់ថ្ពាល់មកបន្ថែមតិចៗលើថ្ងាសនិង ថ្គាមដើម្បីអោយពន្លឺចាំងមកលើមុខស្អាត។

4. Cheek make up: instead of apply cheek color directly on the apple of your cheek, try focusing more on your cheekbone and tune down to the apple of your cheek. Also, add a little tiny bit along forehead and jawline to create a beautiful sun-kissed glow.

5 **ច្រមុះ៖** យកម្សៅផាត់ពណ៌សផាត់លើខ្នង់ច្រមុះតិចៗ និងអោយស្រមោលទៅលើផ្នែកខាងៗនៃច្រមុះដើម្បីអោយវាមើលទៅស្រួចជាងមុន។

5. Nose contour: use white shadow powder to apply a little bit in the straight line of your nose and add shadow on the side for a sharper nose.

6 សាកល្បងប្រើពណ៌ក្រែមលាបមាត់និងថ្នាំក្រចកឬក៏គ្រឿងអលង្ការបន្ថែមផ្សេងៗពណ៌ដូចគ្នាធ្វើអោយអ្នកមើលទៅ ឡូយឆាយដូចបង្ហាញដោយ Model របស់ Sabay Magz ក្នុងទំព័រនេះ! ក្នុងការផាត់មុខនេះ Janny Victory Salonប្រើឈុតផាត់មុខរបស់ផលិតផលម៉ាក Dior ។

6. Bonus: Use the same lipstick color on your nails and if possible, your accessories to get our model's fashion chic look. In this make up, Janny Victory Salon use Dior make up set.

**Tip សម្រាប់សក់រួញស្អាត៖** បន្ទាប់ពីម្ហូរសក់រួចដោយចែកសក់ជាចំណែករួចម្ហូរវា យកក្រាស់សិតសក់ណាដែលធ្មេញក្រាស់មានចន្លោះធំយកមកសិតថ្នមៗ។សក់នឹងមិនស្អិតចូលគ្នាដូចរាល់ដងទេហើយពេលទម្លាក់វាចុះ មកក៏មើលទៅរលាស់ស្អាតដែរ។

Hair Tip for a more natural curl:
After the usual dividing hair into section and curl them, try using a big-tooth comb to brush down your hair. Your curls will cascade down more naturally and not lump altogether like they normally would!






Dior
MAKE UP SET
AVAILABLE AT JANNY VICTORY SALON




# ស្ទូចត្រីលើដងទន្លេមេគង្គ

និយាយពីរឿងទៅដើរ លេងស្ទូចត្រី ស្តាប់ទៅដូចជាប្លែកបន្តិច តែសម្រាប់អ្នកចូលចិត្តចំណាយពេលវេលា ស្វែងរកបទពិសោធន៍ប្លែកៗជាមួយធម្មជាតិវិញ ប្រហែលជាពេញចិត្តហ្មង ព្រោះទំព័រនេះ ទស្សនាវដ្តី Sabay លើកយកសេវាកម្មរៀបចំដំណើរកម្សាន្តមួយ អាចនាំអ្នកទៅស្ទូចត្រីតាមបណ្តោយទន្លេមេគង្គ ព្រមទាំងមើលទេសភាពថ្ងៃលិចនៅទន្លេមុខ ៤ ថែមទៀតផង។ ចង់សាកល្បងសម្រាកកាយនឹងភាពស្ងប់ស្ងាត់នៃដងទន្លេមេគង្គហើយចាប់ត្រីធំៗមកផ្ទះទេ?

Fishing may sound new to readers, but it has been available here in Phnom Penh since 2013. Have you ever gone fishing? Would you like to try a day relaxing by the serenity of the Mekong river while catching some big fish?

Phnom Penh Fishing Tour មានផ្តល់ជូននូវដំណើរកម្សាន្តស្ទូចត្រីលក្ខណៈជាក្រុម និងឯកជនតាមចំណូលចិត្តរបស់អតិថិជន។ ដំណើរកម្សាន្តគឺមានរយៈពេលកន្លះថ្ងៃតាមមាត់ទន្លេ ឬមួយថ្ងៃពេញសម្រាប់ដំណើរកម្សាន្តតាមខេត្តមួយចំនួនដូចជាខេត្តកំពង់សោម និងកំពតជាដើម។

អ្នករៀបចំដំណើរកម្សាន្តស្ទូចត្រី Phnom PenhFishing Tour នេះជាយុវជនអាយុ ២៩ឆ្នាំមកពីខេត្តស្វាយរៀង មានឈ្មោះថាភោគ ដន។

យុវជនដន បាននិយាយរៀបរាប់ថា៖ ដំបូងឡើយលោកមិនមានគម្រោងយកវាមកធ្វើជាមុខរបរអ្វីធំដុំទេតែដោយសារមានមិត្តភ័ក្តិខ្មែរ ជាពិសេសមិត្តជាជនបរទេស គឺគេចាប់អារម្មណ៍ពីការស្ទូចត្រីណាស់ពេលឮលោកទៅស្ទូចត្រីពេលចុងសប្តាហ៍។ក្រោយមកដន ក៏ចាប់ផ្តើមសរសេរពីដំណើរកម្សាន្តរបស់លោកលើ blog និងfacebook ជាហេតុនាំឱ្យការស្ទូចត្រីនេះកាន់តែមានការចាប់អារម្មណ៍លើសដើម។

ដោយសារតែបច្ចុប្បន្ន លោក ដន មិនទាន់មានទូកផ្ទាល់ខ្លួន ដូច្នេះការចេញទូកទៅស្ទូចត្រី គឺមិនមានម៉ោងចេញទូកជាក់លាក់នូវឡើយទេ។ ដន បញ្ជាក់ថា ថ្លៃជួលទូកមានតម្លៃខ្ពស់ហើយពេលខ្លះម្ចាស់ទូកដំឡើងថ្លៃទៀតពេលគេឃើញលោកមានភ្ញៀវច្រើនធ្វើអោយលោកមានការលំបាកហើយពេលខ្លះត្រូវលុបចោលការចេញដំណើរជាមួយភ្ញៀវទៀតក៏មាន។ ឥឡូវនេះPhnom Penh Fishing Tour កំពុងរៀបចំប្រមូលមូលនិធិដើម្បីសង់ទូកខ្លួនឯងផ្ទាល់។

ជាចុងក្រោយ ដន បានបង្ហើបថា ៖ "ប្រសិនបើខ្ញុំមានទូកផ្ទាល់ខ្លួនខ្ញុំនឹងរៀបចំម៉ោងពេលចេញដំណើរទូកអោយច្បាស់លាស់ជាងមុន ហើយនឹងពង្រីកមុខរបរនេះ ដោយបន្ថែមសេវាកម្មធ្វើដំណើរទេសចរណ៍តាមផ្លូវទឹកទៅខេត្តនានាដូចជាខេត្តកំពង់ចាមព្រៃវែងនិងក្រចេះ"។

## ដំណើរកម្សាន្តជាក្រុម

ជាទូទៅធ្វើដំណើរពេលចុងសប្តាហ៍ពីម៉ោង៣ និង៣០ នាទី រសៀល ដល់ម៉ោង ៦ ល្ងាច។ដំណើរកម្សាន្តនាំលោកអ្នកទៅស្ទូចត្រីនៅ២តំបន់ផ្សេងគ្នាចាប់ផ្តើមចេញដំណើរពី កំពង់ផែភ្នំពេញទៅមាត់ទន្លេរួចបន្ទាប់ពីសម្រាកស្ទូចត្រីរយៈពេល ២០ នាទីបន្តទៅកែងទន្លេបាសាក់ដើម្បីមើលថ្ងៃលិច។

## ដំណើរកម្សាន្តឯកជន

នាំភ្ញៀវទេសចរទៅរមណីយដ្ឋាននានាដូចជាខេត្តព្រះសីហនុ កំពត កោះស្ងួត្រជាដើមតាមចំណូលចិត្តរបស់លោកអ្នក។ការធ្វើដំណើរទៅខេត្តព្រះសីហនុមួយយប់សម្រាប់មនុស្ស២៥នាក់យ៉ាងច្រើន Phnom Penh Fishing Tourគិតជូនក្នុងតម្លៃម្នាក់ ២០០ដុល្លារ ក្នុងនោះលោកអ្នកអាចហែលទឹក ស្ទូចត្រី និងធ្វើដំណើរទៅកោះនានាជិតនោះផងដែរ។
ឧបករណ៍ស្ទូចត្រីនិងភេសជ្ជៈមានថែមជូនជាមួយការធ្វើដំណើរ។សម្រាប់ការកក់ទូកធ្វើដំណើរអាចទាក់ទងបានតាមF acebook https://www.facebook.com/PhnomPenhFishingTours

Phnom Penh Fishing Tour provide private and public fishing trips according to customers' request, whether it's a half day trip along the riverside or a full day tour to other provinces such as Kompongsom or Kompot.

Pork Dorn, a 29-year-old Cambodian from Svay Reang, is the very owner of this first fishing tour organized in our city. He learned to fish since he was 6 and still keep up this hobby even after he came to Phnom Penh to continue his study.

"It wasn't planned to be a business at first, but many friends, especially foreigners are interested when I told them how I'm going to spend my weekend. Afterward, I started to write about my lonesome fishing trip on a blog and share it on facebook. Many people commented and seem to be interested." Dorn said.
" Because I don't have my own boat yet, I can't have a fix schedule to adhere to. Boat rental price is high enough as it is and sometimes the owner raise their price extra more when they know I'm having a lot of tourists on board. There are times when the prices are too high and I have to cancel on my clients, " added Dorn.

" If I were to have my own boat, I would organize better and stricter schedule to adhere to, also, I will expand the business by including more services such as cruising to other provinces such as Kompong Cham, Prei Veng, or even Kratie so tourist can explore more of Cambodia by boat,"

About Fishing Tour:

Public tours: Usually a half day trip from 3:30PM to 6pm on weekends, bring tourists to 2 spot. Starting the journey from Phnom Penh port near Wat Phnom, the boat travel to the riverside, in front of the Royal Palace. Then after around 20 minutes, the boat move to the corner of Mekong River and Tonle Bassac where fishers can continue catching more fish and enjoy the view of the sunset by the river.

Private tours: take tourists to Kompong som, Kom Pot, Silk Island, etc, base on request.

Tours can be booked via Facebook or phone number. Fishing equipments and drinks such as mineral water and cola are served free of charge on the board. Contact : https://www.facebook.com/PhnomPenhFishingTours

# Coffee and Cacao Frappe

## គ្រឿងផ្សំ

| | |
|---|---|
| 1. **Espresso** ឬកាហ្វេឆុងរួច | **30ml** |
| 2. ម្សៅកាកាវ | **1**ស្លាបព្រាកាហ្វេ |
| 3. ម្សៅទឹកដោះគោ | **1**ស្លាបព្រាកាហ្វេ |
| 4. ទឹកស្ករ | **45ml** |
| 5. ទឹកដោះគោស្រស់ | **20ml** |
| 6. ទឹកកក | **230g** |

វិធីធ្វើ៖ ក្រឡុកគ្រឿងផ្សំទាំងអស់ចូលគ្នារួចដាក់ក្រែមនិងទឹកសូកូឡាពីលើ។



Prepared by: Mrs. Kek Sokkheng
www.kskcooking.com
Tel: 088 9999 876/012 44 05 44
facebook: KSK Bakery Pastry and Food Center





# ITET ពិព័រណ៍បច្ចេកវិទ្យាដ៏ធំបំផុតដែលយុវវ័យចង់ឃើញរាល់ឆ្នាំ

សហព័ន្ធទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានកម្ពុជា( ICT Federation of Cambodia ) បានរៀបចំព្រឹត្តិការណ៍តាំងពិព័រណ៍បច្ចេកវិទ្យាព័ត៌មាន អេឡិចត្រូនិក និងទូរគមនាគមន៍អន្តរជាតិ ចំនួនបីថ្ងៃគឺថ្ងៃទី ១៤ ដល់ថ្ងៃទី ១៦ វិច្ឆិកា ២០១៤ កន្លងទៅនេះនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ ពិព័រណ៍បច្ចេកវិទ្យាដ៏ធំបំផុតមួយនេះ បានធ្វើឱ្យយុវវ័យស្រលាញ់បច្ចេកវិទ្យាមួយចំនួនធំលើកហេតុផលផ្សេងៗគ្នាថា ITET គួរតែមានរាល់ឆ្នាំ។ តើយុវវ័យទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីការរៀបចំ ITET ?







ប៊ុនលី និស្សិតឆ្នាំទី ៣ ផ្នែកព័ត៌មានវិទ្យានៅសាកលវិទ្យាល័យន័រតុន បានប្រាប់ទស្សនាវដ្តី Sabay ថា ITET បានផ្តល់ព័ត៌មាន ផលិតផល និងបច្ចេកវិទ្យា Update ថ្មីៗជាច្រើនដែលអាចយកទៅសិក្សាស្រាវជ្រាវ និងអនុវត្តន៍លើចំណេះដឹងផ្នែក IT ស្របទៅតាមមុខវិទ្យាដែលប្អូនកំពុងរៀនសព្វថ្ងៃនេះ។

ប៊ុនលី បន្តថា៖ " អ្នកស្រលាញ់បច្ចេកវិទ្យាបើមិនខំស្រាវជ្រាវទេ ប្រហែលដើរមិនទាន់គេទេ ព្រោះបច្ចេកវិទ្យាលើពិភពលោកគេ Update ស្ទើរតែរាល់ថ្ងៃ។ ដូច្នេះមួយឆ្នាំមានព្រឹត្តិការណ៍ធំម្តងអីចឹង ITET គួរតែមានរាល់ឆ្នាំហើយនាំយកអ្វីដែលថ្មីមកបង្ហាញដល់ប្រជាជនខ្មែរទាំងអស់គ្នា "។ ចំណុចដ៏គួរឲ្យចាប់អារម្មណ៍មួយទៀត យុវជន មុន្នីរិទ្ធិ និស្សិតនៅសាកលវិទ្យាល័យស៊ីតិច បាននិយាយថា ក្រៅពីទស្សនាផលិតផលថ្មីៗ ចំណុចពិសេសរបស់ ITET ដែលប្អូនគិតថាល្អនោះ គឺត្រង់មានបុគ្គលបច្ចេកវិទ្យា និងប្រធានក្រុមហ៊ុនបច្ចេកវិទ្យាល្បីៗក្នុងប្រទេសចូលរួមចែករំលែកចំណេះដឹងក្នុងការតាំងពិព័រណ៍នោះតែម្តង។

“ ប៉ុន្មានឆ្នាំមុនខ្ញុំគិតថាក្រុមហ៊ុនធំៗនៅស្រុកខ្មែរមិនទាន់ប្រើបច្ចេកវិទ្យាទំនើបៗដូចស្រុកគេទេតែដល់ពេលមកស្តាប់ Presentation ពីបុគ្គលបច្ចេកវិទ្យាល្បីៗនៅស្រុកខ្មែរនៅ ITET រួចមក ខ្ញុំដឹងថាស្រុកខ្មែរមិនចាញ់បរទេសប៉ុន្មានទេ ជាពិសេសគឺការថែរក្សាទិន្នន័យក្នុងក្រុមហ៊ុនរបស់ពួកគាត់ ”។ មុន្នីរិទ្ធិបញ្ជាក់។

ចំណែកឯយុវតី មួយលី និស្សិតមកពីសាកលវិទ្យាល័យបញ្ញាសាស្រ្ត ក្រោយពីបានចូលរួមទស្សនាការតាំងពិព័រណ៍ ITET រួចមក កញ្ញាចាប់អារម្មណ៍លើចំណុចមួយ ពាក់ព័ន្ធនឹងការបង្ហាញស្នាដៃថ្មីៗរបស់យុវវ័យខ្មែរដូចជា ការផលិតហ្គេមដោយស្នាដៃកូនខ្មែរ Osja Studio និងការអភិវឌ្ឍន៍ក្តាចុចខ្មែរលើ OS Android ជាដើម។

តាមរយៈព្រឹត្តិការណ៍តាំងពិព័រណ៍មួយនេះ មួយលីសង្ឃឹមថា ITET នឹងផ្តល់ឱកាសដល់យុវវ័យមានស្នាដៃជាច្រើនទៀតយកទៅបង្ហាញដល់ប្រជាជនខ្មែរក្នុងកម្មវិធីមួយនេះនៅឆ្នាំក្រោយ។

ពិព័រណ៍បច្ចេកវិទ្យាព័ត៌មានអេឡិចត្រូនិក និងទូរគមនាគមន៍អន្តរជាតិ (ITET) មានក្រុមហ៊ុនបច្ចេកវិទ្យាជាង ៤0 ចូលរួមតាំងបង្ហាញផលិតផលនិងសេវាកម្មក្នុងឆ្នាំ ២០១៤ នេះ។ ការរៀបព្រឹត្តិការណ៍ដ៏ធំដើម្បីឲ្យប្រិយមិត្តស្រលាញ់បច្ចេកវិទ្យាបានទិញ និង ឃើញបច្ចេកវិទ្យាថ្មីៗនៃពិភពលោកនេះគឺមានការសហការយ៉ាងជិតស្និទ្ធពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា៕



## CHRISTMAS និង NEW YEAR នៅ KIDS CITY

# ល្បែងកម្សាន្តឥតឈប់ឈរ !

### This Christmas and New Year Fun on the Run at Kid City!



ប្រសិនបើមិត្តអ្នកអានមិនទាន់មានគម្រោងអ្វីបុណ្យ Christmas នេះទេ សាកល្បងទៅកម្សាន្តនៅ Kid City ដែលនឹងមានរៀបចំកម្មវិធីកម្សាន្តហូរហៃ។ One-Day Pass បានត្រលប់មកវិញហើយ ដោយគ្រាន់តែចំណាយ $25 អ្នកអាចលេងកម្សាន្តបានគ្រប់យ៉ាងនៅ Kids City សម្រាប់បុណ្យ Christmas និង New Year នេះ! បន្ថែមលើនេះទៀតអ្នកនឹងទទួលបានភេសជ្ជៈ១កែវ ឬ ការ៉េម១ទៀតពី Gloria Jean's Coffee, Poptea ឬ The Blue Pumpkin ដែលមាននៅក្នុងអាគារ Kids City ស្រាប់តែម្តង!!

អ្នកគ្រប់គ្រងផ្នែករៀបចំកម្មវិធីនៅ Kids City ឈ្មោះ Lara M. Martin បានរៀបរាប់ថា ទោះបីជាបុណ្យ Christmas ជាវប្បធម៌របស់អឺរ៉ុបក៏ដោយតែប្រជាជនយើងពេញនិយមចូលចិត្តកម្មវិធីនេះដែរ។ ក្នុងនាម Kids City ជាមជ្ឈមណ្ឌលកម្សាន្តឈានមុខរបស់ព្រះរាជាណាចក្រកម្ពុជាសម្រាប់កុមារក៏ដូចជាយុវវ័យ នឹងមិនធ្វើឲ្យលោកអ្នកខកចិត្តឡើយដោយផ្តល់ជូនការកម្សាន្តបន្តបន្ទាប់គ្នាសម្រាប់បុណ្យ Christmas និង New Year នេះ។

ចាប់ពីថ្ងៃទី ១៣ដល់ថ្ងៃ២៥ ខែធ្នូ អ្នកនឹងបានជួប Santa Claus ស្តាប់ការច្រៀងចម្រៀង Christmas និងមានការតុបតែងអោយមានបរិយាកាសបែបថ្ងៃបុណ្យនេះផ្ទាល់តែម្តង។ ក្រៅពីនេះ Kids City មានរៀបចំ កម្មវិធី ហ្គេមកម្សាន្តជាច្រើនមានគ្រប់ជាន់។ ក្នុងនោះ Sabay Magz លើកយកសកម្មភាពហ្គេម ៤មកបកស្រាយ៖

តាមរកពាក្យ៖ កុមារគ្រប់អាយុទាំងអស់អាចលេងបាន ដោយប្រណាំងគ្នាតាមស្វែងរកពាក្យដែលពាក់ព័ន្ធនឹងបុណ្យ Christmas ផ្សេងៗ មកបង្កើតជាពាក្យ។

ដេញចាប់ Santa៖ Christmas ម៉េចនឹងសប្បាយបើអត់មាន Santa Claus! ឆ្នាំនេះគាត់នឹងលាក់ខ្លួនពួនក្នុងតំបន់ Laser Tag arena របស់ Kids City។ ប្រមូលគ្នាមកតាមរក Santa ទាំងអស់គ្នាបើមិនអីចឹងទេមិនបានកាដូទេ!

ឡើងជញ្ជាំង៖ ត្រៀមខ្លួនឬ នៅដើម្បីប្រយុទ្ធឡើងជញ្ជាំងបំផុតនៅKids City ? សាកមើលកម្លាំង និងភាពក្លាហាន របស់អ្នកលមើលអាចឡើងទៅដល់កម្ពស់ខ្ពស់ជាងគេឬអត់ ?មានរង្វាន់ជិះ Vertical Slides និង Leaps of Faith សម្រាប់អ្នកឈ្នះ!ព្រិលធ្លាក់នៅ Kids City ៖ ពួកមនុស្សតឿរបស់ Santa នឹងបង្រៀនអ្នកអោយបង្កើតព្រិលដោយខ្លួនឯង ហើយអ្នកអាចសម្រូតខ្លួនចុះមកយ៉ាងសប្បាយដោយប្រើស្គីព្រិលពិសេសដំណើរការដោយមានជំនួយពីប៉េងប៉ោងធំ ( បាឡុង )។ ក្រៅពីថ្ងៃបុណ្យ Christmas នៅ Kids City ក៏មានផ្តល់ការកម្សាន្តសម្រាប់ឆ្នាំថ្មីដែរ ដោយ នៅថ្ងៃទី១ មករា មានផ្តល់ជូនសំបុត្រចូលរួមកម្សាន្ត១សន្លឹកទៅក្មេងទុរភិក្សរាល់ការចំណាយអស់$20 របស់លោកអ្នក។ ចាប់ផ្តើមឆ្នាំថ្មី ឆ្នាំ2015 ដោយចែករំលែកការសប្បាយទាំងអស់គ្នា!

What are your plans this Christmas? Look no further: if you want to experience Christmas like no other ,go to Kids City where activities will be packed ready awaiting you to have fun. And the breaking news this year is that the One-Day Pass is back to Kids City for Christmas and New Year's! For $25 you will get unlimited access to all games plus one drink or ice cream at Gloria Jean's Coffee, Poptea or The Blue Pumpkin: all without moving from Kids City!

Lara M. Martin, events manager of Kids City expressed her idea that even though Christmas is more of a western culture festivity, Cambodian people are now getting more and more attracted to the event. As the best entertainment center for children and grown-ups in town, Kids City surely won't fail to amaze you with unlimited fun and activities for the upcoming Christmas and New Year celebration.

Besides Santa's visit from the 13th onwards Christmas, the unmissable carols and the merry atmosphere, there will be –of course- special games and competitions on every floor of Kids City: it's a non-stop celebration and Sabay Magz selected for you its 4 favorite happenings there.

Word Hunt: At Go-Karts children of all ages will find the fun as they hurry to find spare words on one side of the floor and race again to build the complete Christmas sentences on the other side of the circuit.

Chasing Santa: There's no fun without Santa Claus indeed, and it turns out that this year he has decided to hide at Kids City's Laser Tag arena! Get your group of friends ready to laser-tag as many Santas as possible and releasing them before the night of the 24th. Otherwise, no Christmas presents for anyone!

Climb the hardest wall: Are you ready for the most challenging activity in Kids City this Christmas? Test your strength, balance and endurance and be the one to reach the top. Free Vertical Slides and Leaps of Faith are awaiting the bravest ones!

Snow making and Balloon-powered sleigh workshops: Santa's dwarfs are ready to teach you how to make snow and build Santa's sleighs to slide all the way down with a powerful balloon! You don't believe us? Take a look at their Science floors!

On the 1st of January Kids City will have a big give away event. For every $20 spent in one single receipt during December, Kids City will donate one free pass to disadvantaged children in partnership with selected NGOs. Be kind to one another. Let's start 2015 with actual fun for everyone!



甜品屋 **dessertstory**
TAIWANESE & HONG KONG DESSERT SECRETS

# រឿងដែលអ្នកគួរដឹង DESSERT STORYមាននៅកម្ពុជា


Facebook: Dessert Story Cambodia

ហាងលក់បង្អែម Dessert Story ដែលមានសាខាជាច្រើននៅបរទេសពេលនេះបានមកដល់ប្រទេសកម្ពុជាហើយ ដោយបានបើកសាកល្បងហាងនៅថ្ងៃទី 26ខែវិច្ឆិកានេះ ។ព្រឹត្តិការបើកសាកល្បងមានការចូលរួមផ្ទាល់ពីម្ចាស់សិទ្ធិ លោក  David Loh ក៏ដូចជា តារាសិល្បៈ ល្បីៗជាច្រើនរូបទៀត។

Dessert Story ជាហាងបង្អែមល្បីមកពីប្រទេសអូស្រ្តាលីដែលបានបង្កើតឡើងដោយម្ចាស់ហាង លោក David Loh។ ព្រោះតែចំណាប់ចំណូលចិត្តចំពោះបង្អែមបែបអាស៊ី លោក David Lohធ្វើដំណើរទៅកាន់ ហុងកុងនិងតៃវ៉ាន់ដើម្បីសិក្សាអោយកាន់តែច្បាស់អំពីសិល្បៈធ្វើបង្អែមចេញពីគ្រឿងផ្សំស្រស់ពីធម្មជាតិថ្មីៗ។បន្ទាប់ពីនោះមក គាត់ត្រលប់មកប្រទេសអូស្រ្តាលីដើម្បីបើកហាងបង្អែមនេះ។ បច្ចុប្បន្ន ហាងរបស់គាត់មានសាខាជាច្រើនក្រៅប្រទេសតាមទីក្រុងនានា15សាខានៅប្រទេសអូស្រ្តាលី 6សាខានៅប្រទេសចិននិង ឥលូវនេះមានសាខាដំបូងនៅកម្ពុជា ហើយហាងទី២ក៏នឹងមានគម្រោងបើកដើមឆ្នាំខាងមុខនេះដែរនៅTK Avenue។

សេង ទូស៊ីត្តា ជាម្ចាស់ហាងសាខានៅកម្ពុជា បានរៀបរាប់ថា ការដែលនាំយកនូវបង្អែមនេះមកស្រុកខ្មែរ គឺដោយសារតែនៅប្រទេសយើងពុំទាន់បានសាកល្បងបង្អែមថ្មីបែបនេះនៅឡើយ។ បង្អែមនៅDessert Story គឺចម្អិនផ្ទាល់ដោយដៃប្រើប្រាស់គ្រឿងផ្សំស្រស់ ដូចជា សណ្តែក តៅហ៊ូ និងដំឡូង ជាដើម។រសជាតិនៃ បង្អែមគឺឆ្ងាញ់ប្លែកពីគេ។

បង្អែមនៅ Dessert Story ជាការផ្សំឡើងនូវបង្អែមបែប ហុងកុងនិងតៃវ៉ាន់ បង្កើតបានជាងបង្អែម100មុខដែលនៅក្នុងនោះ តម្លៃមានចាប់ពី1.5$ ទៅ 6.2$។ ដូចនេះ ហើយការមកសាកល្បងភ្លក់រសជាតិនៅ Dessert Storyធានាថាមិនខកចិត្តទេ ព្រោះមានជម្រើសច្រើនសម្រាប់អ្នកហើយតម្លៃក៏សមរម្យផងដែរ។

Dessert Story franchise in Cambodia celebrated its soft opening on the 26th November, 2014. The event was honored by founder of the franchise, Mr. David Loh and many honorable guests.

Dessert Story is a renowned well-established dessert paradise franchise from Australia. Founded by Mr. David Loh, whose passion for home-style sweetness take him to Hong Kong and Taiwan to learn more about those ingredients before he decided to share this excellent recipe in Australia. Now Dessert Story has many stores that can be found in many countries and cities in Australia, China and this is the first store in Cambodia. The second shop will be open early next year in TK Avenue.

Ms. Seng Tousitta , owner of the Cambodian franchise branch stated that she wanted to bring this dessert to Cambodia because this Asian dessert culture is something new and not found in here yet. Desserts here are hand-made from natural ingredients such as beans, tofu, and yams. It's all very fresh and delicious, so the key here is the taste.

The dessert combine the taste of Taiwan and Hong Kong style dessert and the menu feature over 100 products in the shop ranging from herbal jelly series, pudding series, taro ball series, glutinous rice series, crushed ice series, to snow ice series. There's bound to be something you like, said Mr. David Loh. Price range is from 1.5$ to 6.2$ which is affordable for everyone.



No.294, St 51
Sangkat Boeung Keng Kong1, Khan Chamkamon
Phnom Penh, Cambodia (Opposite to Needa Bar)
Email: info@dessertstory.com.kh
Tel: 071 696 9999/ 069 833338




# ហោរាសាស្ត្រ ប្រចាំខែធ្នូ ២០១៤

HOROSCOPE FOR DECEMBER 2014

**ឆ្នាំជូត Rat**

នរណាៗក៏មានកំហុសដែរ។ តែបើអ្នកមានកំហុសអីមួយនោះ អ្នកនឹងមានអ្នកចាំជួយប្រាប់ពីកំហុសរបស់អ្នក ហើយអ្នកនឹងទទួលយកការកែលម្អ របស់គេ។ រឿងលុយកាក់៖ គិតឲ្យបានច្បាស់មុននឹងទិញអ្វីមួយ ជៀសវាងគេកោ។ស្នេហា៖ និយាយត្រង់ទៅត្រង់មកជាមួយគូស្នេហ៏កុំនៅចាំតែស្មុគស្មាញស្មានអ្វីៗ តែខ្លួនឯង។

Humans make mistakes. If you make a mistake and somebody points it out, you will gladly concede that they have a fair point. Money: think carefully before you buy anything, you'll be probably be overcharged. Love: Don't keep on guessing your lover's move. Be straight forward to avoid conflict.

**ឆ្នាំរោង Dragon**

ដោយសារអ្នកមិនពេញចិត្តពីការរស់នៅរាល់ថ្ងៃ អ្នកនឹងគិតពីវិធីផ្សេងៗ ដើម្បី ទទួលបានការប្រែប្រួលខ្លាំងតែត្រូវប្រយ័ត្ន មុននឹងធ្វើអ្វីមួយត្រូវគិតអោយបានច្បាស់លាស់។រឿងលុយកាក់៖អ្នកមានការគ្រប់គ្រងលើការចាយវាយបានល្អ។ស្នេហា៖ អ្នកមានចិត្តក្លាហានដូចរាល់ដងនិងហានចាប់ផ្តើមអ្វីដែលថ្មី។ It can be tempting to think that drastic changes are needed because you are not quite content with what is happening at present. Before you take any action, talk about what is bothering you with someone who also understands the situation you are in at the moment. Money: You're in controlled of spending which is something to be proud of! Love: You'll be as bold as ever, taking initiative in your love life.

**ឆ្នាំវក Monkey**

ពេលមើលបញ្ហាដែលកំពុងកើតមានកាន់តែ ច្បាស់ ទើបអ្នកដឹងថាបញ្ហាដែលអ្នកមានវាស្មុគស្មាញជាងអ្វី ដែលអ្នកគិតទៅទៀត។រឿងលុយកាក់៖អ្នកនឹងរកនឹកឃើញវិធីដែលធ្វើឲ្យលុយកាក់ដែលអ្នកមានប្រើទៅបានគ្រប់គ្រាន់។ស្នេហា៖ អ្នកអត់គូអាចនឹងរកបានគូស្នេហ៏ក្នុងខែនេះ។ When you examine the spot of trouble in more detail, you realize you are dealing with a situation that is far less complex than everyone else has made it out to be. Money: You can find a clever way to make the cash stretch. Love: If you are an unattached Monkey, you might simply need to make a conscious choice to change your status.

**ឆ្នាំឆ្លូវ Ox**

ការងារដែលអ្នកធ្វើបានផលល្អជាងមុន ជាងអ្វីដែលស្មានទុក។ រឿងលុយកាក់៖ដោយសារអ្នករៀបចំចំណាយបានល្អ ខែនេះអ្នកនឹងមានប្រាក់កាសគ្រប់គ្រាន់ដើម្បីចាយសប្បាយខែ នេះ។ស្នេហា៖ ទំនាក់ទំនងការនិយាយស្តីជាមួយដៃគូមិនបានគ្រប់គ្រាន់អាចប៉ះពាល់ដល់ជីវិតស្នេហារបស់អ្នក។

It is becoming apparent that the result is going to be better than you had hoped for. Give yourself credit for working smart rather than working hard. Money: Very organized, you're going through the month just fine. Love: Pay more attention to your love life, lack of communications is messing with you.

**ឆ្នាំម្សាញ់ Snake**

អ្នកដឹងពីអារម្មណ៍ប្រែប្រួលមួយចំនួនរបស់ខ្លួនឯងដែលអាចធ្វើឲ្យអ្នកស្ងប់ចិត្តដើម្បីបំពេញការងារសំខាន់ៗ ផ្សេងៗ។រឿងលុយកាក់៖ជៀសវាងការទិញទំនិញពេលអ្នកមានអារម្មណ៍មិនល្អ។ស្នេហា៖ នឹកមានអ្នកតាមចែចង់ពេញចិត្តអ្នក ។ Being aware of the sort of mood you are in and how you can shift your frame of mind will mean you can pull yourself together when you want to do something important. Money: Avoiding shopping, both on your feet and online, when you are feeling a bit glum could save you money and save you time if you change your mind about any impulse purchases. Love: Keep your heart open this month

**ឆ្នាំរកា Rooster**

មានរឿងមួយចំនួនមិនគួរនិយាយទៅកាន់មនុស្សដែលប្រកាន់ច្រើនឡើយ។អ្នកអាចចាប់ផ្តើមសន្ទនានឹងគេមុនប៉ុន្តែកុំនិយាយច្រើន ចាំតែស្តាប់ទៅបានហើយ។ រឿងលុយកាក់៖មិនចាំបាច់គិតច្រើនពេកទេមុននឹងទិញ ឥវ៉ាន់។ ស្នេហា៖ ទំនាស់អាចនឹងកើតឡើងបានពីការពិភាក្សា។

It often feels easier not to tell things to those who are easily upset. You can initiate the dialogue, but do not think you need to do all the talking. It is far more important for you to do more of the listening. They might have been waiting to cry on your shoulder. Money: be wary of over-thinking about your purchases. Love: Conflict may arises from the discussion.

**ឆ្នាំខាល Tiger**

អ្នកនឹងរីករាយដោយបញ្ហាផ្សេងៗដែលអ្នកគិតថាអាចនឹងកើតមានក្លាយជាលាភសំណាងវិញ។រឿងលុយកាក់៖អ្នកនឹងមានលុយកាក់ហូរហៀរសម្រាប់ចាយក្នុងខែនេះ។ស្នេហា៖ ទំនាស់ក្នុងរឿងស្នេហានឹកកើតមានឡើង។ ព្យាយាមយល់ចិត្តថ្លើមរបស់ដៃគូអ្នកខ្លះផងទៅ។

You can now feel glad that you waited to see how events unfolded because what you thought was unwanted is turning out to be something that is just the ticket. There is no longer any need to think about you will cope with the situation. Instead, you will think about how you can make the most of it and thrive. Love: conflict arises, you need to be more understanding of your lover! Money: You got money to blow. Enjoy the festive season!

**ឆ្នាំមមី Horse**

មានពេលខ្លះកាយវិការរបស់អ្នកអាចមើលទៅមិនសមគួរ កុំអោយតម្លៃកាដូដែលទទួលបានតាមតម្លៃទឹកប្រាក់របស់វា។រឿងលុយកាក់៖ឲ្យតម្លៃលុយកាក់ដែលរកបានខ្លះផង មិនត្រូវទូលាយដៃពេកទេ។ ស្នេហា៖ អ្នកនឹងទទួលបានកាដូទាំងសន្ធឹកពីមនុស្សជាទីស្រលាញ់។ There are times when it would not be considered good manners to appear ungrateful by focusing on the value of a present, especially in front of the person who gave it to you. Bear in mind that when it comes to gifts, it can be the thought that counts for a lot more than the amount spent. Money: Remember to apply more sense than money. Love: be prepared to be pampered with gifts from your loved one.

**ឆ្នាំច Dog**

អ្នកមិនចង់រវល់នឹងរឿងរបស់អ្នកដទៃឡើយ ព្រោះរវល់ទៅ នាំតែបានបន្ទុកការងារច្រើនជាងមុន។រឿងលុយកាក់៖អ្នកអាចនឹងខ្វះ ថវិកាសម្រាប់កាដូដែលត្រៀមទុក។ស្នេហា៖ បរិយាកាសគូស្នេហ៏មានភាពរ៉ូមែនទិកជាងធម្មតា។

The last thing you want is drama-involving people you care about most. Equally worrying is situations involving various responsibilities or perhaps works. Money: Your short of money from all the gifts preparation. Love: Romantic atmosphere arises. Have fun counting down with your lover.

**ឆ្នាំថោះ Rabbit**

អ្នកមិនដលែរករឿងនរណាឡើយតអែាចមានរឿងដោយសារអ្នកលើកឡើងពីបញ្ហាដែលអ្នកដ៏ទៃធ្វើមិនគាប់បីចំពោះអ្នកទៅវិញ។រឿងលុយកាក់៖អ្នកអាចនឹងចាយលើសពីការកំណត់ដោយចង់បានរបស់ថ្លៃៗមកបង្អួតអ្នកដទៃ។ស្នេហា៖ សំណាងល្អនឹងមានក្នុងជីវិតស្នេហារបស់អ្នក។ You have no wish to tread on other people’s toes, yet you would only be asserting your own boundaries, which they had crossed, by pointing out why you were less than impressed by their words. Money: Be wary of thinking you need to purchase luxuries in order to impress people. Love: Your Rabbit personality is romantic at heart, and the Rat ruling the month can bring romance luck to your sign.

**ឆ្នាំមមែ Goat**

អ្នកត្រូវមើលពីកំហុសដែលបានកើតឡើងនៅឆ្នាំចាស់ ហើយនឹងត្រៀមខ្លួនកែប្រែឲ្យបានល្អជាងមុនសម្រាប់ឆ្នាំថ្មីដែលនឹងមកដល់។រឿងលុយកាក់៖កុំខ្ជះខ្ជាយលើឥវ៉ាន់ថ្លៃៗ ដែលអ្នកមិនត្រូវការ។ស្នេហា៖ សម្រាប់ខែនេះឆ្នាំមមែមានភាពរ៉ូមែនទិកជាងគេ។

It is only with hindsight that you can see at which points things started going wrong. If you get a sense of déjà vu, you can see it as a chance to apply the lessons learned from what did not quite go according to plan earlier this year. Money: Don't waste money on overly expensive clothing and jewelry, Money can't buy class. Love : Paired-off Goats, you can make the most of the romantic atmosphere by making some special plans with your beloved.

**ឆ្នាំកុរ Pig**

ការសម្រេចរឿងផ្សេងៗអាចនឹងរឿងមិនចេះចប់ ដូច្នេះរាល់ការសម្រេចរបស់អ្នក ត្រូវតែប្រុងប្រយ័ត្នឱ្យបានល្អិតល្អន់។រឿងលុយកាក់៖ កុំដៃទូលាយពេក ទុកដាក់លុយកាក់ដែលរកបានខ្លះទៅ។ ស្នេហា៖ មានការប្រែប្រួលខ្លះក្នុងជីវិតស្នេហាប៉ុន្តែវាជារឿងល្អទេ។

Just when you thought you had got the right idea about something, or about someone, you make a new discovery, and learn that what you had learned is not quite right. Money : If you are aware that there are improvements that can be made when it comes to managing your money, you need to avoid being overly open-handed. Love: Do not be afraid of changes in your relationship. It's changing for the better.




# PICK UP SABAY MAGZ TODAY

## OVER 400 OUTLETS AND COUNTING

**A**
At home
3 Mangos Eden's
A.N.D
Adidas
Air France Agency
AIS
Alliance Pharma Cambodge
Amara Spa & Shop
Amber House
AMED Clinic
Angkor CamView Tours
Angkor Spa
ANZ royal Bank
Artillery Café
Artwood
AsIAN Kitchen

**B**
Bar Italia
Bar Sito
BBW City Mall
BBW Sorya 2nd floor
BBW Sovanna
Beeline
Bloom Café
Blue Dog
Blue Pumpkin
Bon Bon Ice Cream
Brew House Café
Build Bright University
Burger King - AIRPORT

**C**
Café Bean Monivong
Cambodia Brewery Limit
CBM
CD World
Cosmopolitan
Costa Café
Costa Coffee
Couleur Coffee

**D**
Dairy Queen - AIRPORT
Dao Café
Deco
Decosy
Digi

**E**
E-Optic
Equinox Bar
Esspresso Café
Ezecom 3rd floor

**F**
Flavors of India
Flavour Restaurant
Fox Wine Bistro
Freebird
Frizz

**G**
G Eleven
G-Cam Watch
Gasolina
Gloria Jean
Gong Cha
Green of Farm

**H**
Hanuman Tour
Hanuman Traditional Art
Herb Café
Holika Cusmetic
Honda Sushi
Hope World Wide Medical

**I**
i-Qlick
iFood Restaurant & Soup

**J**
Jasmine Boutique
Jiggsy Tea
Jojo Green Tea

**K**
Kabas Tailors
Kashaya Silk
Katiya Shop
KaViar
Keokjay
Khmer Surin Restaurant
Khmerittute
Kids City
King Grand Hotel
King Grand Suite Hotel
Kiriya Café
Kiwi Mart
Koi Café
KTM Motorcycle

**L**
Le Café
Le Duo Bar
Le Jardin
Le Marais
Le Temps Des Cerises
Legend Cinema
Lezard Bleu
Lina Boutique
Liquid Bar
Living Room Café
Liz House of Beauty
Lotus
Lotus Bars & Café
Lotus Luxery Villa
Luggaga Gallery
Luna Shoes
LUV Brand Boutique

**M**
Mama New York Deli
Manulife, 8th floor
Mart In & Out
Mega
Mekong Creation
Mekong Kilt
Metfone (Ms. Jessica)
Milk Green Tea TTP
Mini Banana
Ministry of Information
Mobitel
Moly Care Car wash
Mommy BBQ Soup
Monkey Business
Mosaic Gallery
Mother In Law Restaurant
Mother In Law Restaurant
Motor Image - Sabaru

**A**
Mount Everest
Mount Manaslu
Mt. Manaslu

**N**
Narita Vespa
Nata Spa
New Golden Bridge
Nike's Pizza
Nine Star Spa
NOM
Norton Uni New Campus
Norton Uni Old Campus

**O**
Ocean Restaurant
Ochaya Tea
One Up Banana
Open Wine Restaurant
Orchid Spa

**P**
Pachem Dental
Pachem Dental Norodom
Pachem Dentist
Palm Tours
Panda Massage
Panda Massage
Pannasastra University
Pannasastra University
Paperdolls
Passion Spa
Patio Hotel
Peace Handcrafts & Silk
Penh Jet
Phibious
Phkar Romyool Restaurant
Phnom Penh City Hotel
Phnom Penh City Mart
Pizza World
Pizza World City Mall
Pizza World Ratanak Plaza
Platinum Cineplex
Pleasure Restaurant
Poly's Class
Preap Sovath Hair Cut

**Q**
qb
Queen Boutique
Quick Stop Food Mart

**R**
Red Apron
Red Ochid
Relax
Ripple Café
River Ochid
Romdeng
Rooms & Spa
RUPP Book Store 1
RUPP Book Store 2

**S**
Saffron
SaMaKy Rest. & Lounge
Sawadee Goldie Guesthouse
Score Bar
Sinan Rstaurant
Sleuk Teuy Restaurant
Smart (Marketing)
Smart Sport Ly Ly Mart
Smateria
Smile Mart
Sofia Hotel
Sofiya Tour
Sokha Club Hotel
Solidus
Solinna Salon
Spicy Green Mango
Spinelli Café

**S**
Steave Steak House
Steave Steak House
Subtyl
Succogene Café
Sugar Palm
Suite Home Boutiqe
Sunshine Mart
Super Fit Gym
Sushi Been
Swiss Watch Center

**T**
T&C
T&C City Mall
Tapas
Tarana Asian Kitchen
Tea Art
Tela Mart
Tela Mart
Tele Mart
Tendance Khmere
Terrazza
The 240
The Emerald Lotus Boutique
The Latin Quarter
The Mad Monkey
The Mou Café
The Pavilion
The Plantation Hotel
The Taste
The White Maison
theWarehouse
Tips & Toe
TLJ Preh Sihanouk
TLJ Sovanna
Tom Yum Kong

**U**
USA Donut

**V**
Vanda Institute
Vegetarian
Veggys
Vego Salad Bar
Villa Boran Boutique
Villa Samnang
Villa Samnang
VIP Mini Mart
VIP Pho Restaurant
Vtea

**W**
Wanderlust
Western University
Western University
White Lotus Spa
Wild Wing Restaurant
Wing
Wings Café
WTT Advertising
Wuttisak Clinic
Wuttisak Clinic

**Y**
Yi Ren Garden Restaurant
yoshinoya
Yves Rocher

**Z**
Zaman University


២០១៤
អរគុណដែលបានធ្វើឲ្យ sabay
ក្លាយជាគេហទំព័រលេខ១
news.sabay.com.kh
Scan here for latest news updates